# សុវណ្ណសាមជាតក



នេះកាលព្រះសុវណ្ណសាមសម្តែងធម៌ប្រោសបិឡិយក្ស

ដឹកនាំការរៀបរៀងដោយ
ខ្ញុំព្រះករុណាខ្ញុំបាទ
**កុល ផេង**

**ព.ស. ២៥៦៣**

## សុវណ្ណសាមជាតកពិស្តារ

**អធិបតីក្នុងការរៀបរៀង**
**បណ្ឌិត កុល ផេង**
*ប្រធានសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*
*និងជាប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*
*នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**អ្នកបកប្រែពីអដ្ឋកថាភាសាបាលី**
*លោក* **គង់ សំអឿន** *និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា*

**ក្រុមជំនុំពិនិត្យ**

*បណ្ឌិត* **កុល ផេង** *ប្រធាន*

*ព្រះភិក្ខុ កិត្តិបាលោ* **ពេញ វិបុល**

*ព្រះភិក្ខុ វជិរប្បញ្ញោ* **គូ សុភាព**

*បណ្ឌិត* **ប៉ក់ ថាវិន**

*បណ្ឌិត* **សុខ កុសល**

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សាវ៉េន** *អគ្គលេខាធិការពុទ្ធិកបណ្ឌិតសភា*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ**

*លោកគ្រូ* **លឹម លឿម**

*លោកគ្រូ* **ដុង សុភឿន**

*លោកគ្រូ* **ឌិញ្ញ សៅ**

*លោកគ្រូ* **សំណាង សំណាក់**

*លោកគ្រូ* **ស៊ីន់ គឹមឈន់**

*លោកគ្រូ* **កុល ចាន់ថន**

*លោក* **ហាន សុខេមន្ទ** *លេខាធិការ*

**ក្រុមបច្ចេកទេស និងរចនា**

*លោក* **ម៉ម ម៉ានិត** *ប្រធាន*

*លោក* **ឃុន សុវណ្ណរិទ្ធិ** *វិចិត្រករ សមាជិក*

**រចនាសម្ពន្ធពុទ្ធិកបណ្ឌិតសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**ក្រុមប្រឹក្សាភិបាល និងស្ថាបនិក**

*បណ្ឌិត* **កុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ បណ្ឌិត* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*ព្រះញាណកោសល* **យ៉ន សេងយៀត** *សមាជិក*

*ព្រះមហា* **សុន្ទរ៍ សាមឿន** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*បណ្ឌិត* **សំ សំអាង** *សមាជិក*

*បណ្ឌិត* **ម៉ក់ ថាវិន** *សមាជិក*

*សាស្ត្រាចារ្យ* **ម៉ក់ វ៉ាន់** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ហេង គឹមហោ** *សមាជិក*

*សាស្ត្រាចារ្យ* **ជិត ជន** *សមាជិក*

*សាស្ត្រាចារ្យ* **ជា គ្រិស្នា** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ គុយ** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

## ក្រុមជំនុំប្រតិបត្តិ

*បណ្ឌិត* **គុល ផេង** *ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*ព្រះញាណវង្ស* **ឃឹម សន** *ឧត្តមប្រឹក្សាពុទ្ធិកបណ្ឌិតសភា*

*ព្រះធម្មឃោសាចារ្យ បណ្ឌិត* **ឃី សុវណ្ណរតនា** *អនុប្រធាន*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉េន** *អគ្គលេខាធិការ*

*ព្រះមហា* **គូ សុភាព** *ប្រធានគណៈកម្មការបច្ចេកទេស*

*លោកគ្រូ* **ហ៊ាត ណាហាំ** *ប្រធានរដ្ឋបាល*

*លោក* **ហាន សុខេមនុ** *សមាជិកគណៈកម្មការបច្ចេកទេស*

## ក្រុមជំនុំអប់រំសីលធម៌ និងស្រាវជ្រាវអក្សរសិល្ប៍

*បណ្ឌិត* **គុល ផេង** *អធិបតីក្រុមជំនុំ*

*ព្រះធម្មឃោសាចារ្យ បណ្ឌិត* **ឃី សុវណ្ណរតនា** *សមាជិក*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*ព្រះមហា* **គូ សុភាព** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*បណ្ឌិត* **សុខ កុសល** *សមាជិក*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោក* **គង់ សំអឿន** *សមាជិក*

*លោកគ្រូ* **ហួយ វ៉ាន់ថន** *សមាជិក*

## ក្រុមជំនុំផ្សាយព្រះធម៌ និងភាសាបាលី

*លោកគ្រូ ធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *ប្រធាន*

*លោកគ្រូ* **ហ៊ាត ណាហំ** *សមាជិក*

*លោកគ្រូ* **ចាន់ ហួរ** *សមាជិក*

*លោកគ្រូ* **ហួយ វ៉ាន់ថន** *សមាជិក*

*លោក* **សំ សុផល** *សមាជិក*

## ក្រុមជំនុំពិនិត្យ និងបោះពុម្ពផ្សាយសៀវភៅធម៌

*ព្រះមហា* **គូ សុភាព** *ប្រធាន*

*លោកគ្រូ* **លឹម លឿម** *អនុប្រធានទី ១*

*លោក* **គង់ សំអឿន** *អ្នកបកប្រែពីភាសាបាលី អនុប្រធានទី ២*

*ព្រះមហា* **ពេញ វិបុល** *សមាជិក*

*លោកគ្រូធម្មានន្ទ* **វ៉ាន់ ចាន់សារ៉ែន** *សមាជិក*

*បណ្ឌិត* **សុខ កុសល** *សមាជិក*

*ព្រឹទ្ធាចារ្យ* **ដាំ កុយ** *សមាជិក*

*ធម្មាចារ្យ* **ហ៊ាត ណាហាំ** *សមាជិក*

*លោក* **ហាន សុខេមន្ត** *សមាជិក*

*លោកគ្រូ* **សំណាង សំណាក់** *សមាជិក*

*លោកគ្រូ* **ជុង សុភឿន** *សមាជិក*

*លោកគ្រូ* **កុល ចាន់ថន** *សមាជិក*

**សូមថ្វាយព្រះរាជកុសល**

**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង**

**ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**

**នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**

**បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង**

*តាងនាមសមាជិកសមាជិកា ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបបង្គំទូលថ្វាយ ព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ចំពោះ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពស់ខ្ពស់បំផុត ។*

*ទូលព្រះបង្គំសូមថ្វាយព្រះរាជមហាកុសល ដែលទូលព្រះបង្គំខ្ញុំព្រះករុណាទាំងអស់គ្នា បានប្រែសម្រួលនិងរៀបរៀងនូវសៀវភៅ* **សុវណ្ណសាមជាតកពិស្តារ** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមព្រះករុណាជាអម្ចាស់អនុមោទនានូវមហាកុសល ដោយព្រះរាជហឫទ័យជ្រះថ្លាដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់ដឹងកន្លងមកក្នុងលោក ហើយនឹងត្រាស់ក្នុងអនាគត និងដោយតេជានុភាពគុណបុណ្យព្រះរតនត្រៃ*

*ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានី គ្រប់ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលរក្សា* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ពោធិព្រឹក្សដល់ប្រជានុរាស្រ្ត ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្តចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ*

*ថ្ងៃពុធ ៥ កើត ខែមាឃ ឆ្នាំ វក អដ្ឋស័ក ព.ស. ២៥៦០*

**កុល ផេង**

*ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា*

*នៃសាកលវិទ្យាល័យបញ្ញាសាស្រ្តកម្ពុជា*

# សូមថ្វាយព្រះរាជកុសល
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
# ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

## សម្តេចព្រះមហាក្សត្រី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ និងភរិយាព្រមទាំងបុត្រ សូមលំឱនកាយក្រាបបង្គំទូលថ្វាយ ព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ចំពោះ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពស់ខ្ពស់បំផុត ។*

*ទូលព្រះបង្គំសូមថ្វាយព្រះរាជមហាកុសល ដែលទូលព្រះបង្គំខ្ញុំព្រះករុណាទាំងអស់គ្នា បានប្រែសម្រួលនិងរៀបរៀងនូវសៀវភៅ* **សុវណ្ណសាមជាតកពិស្តារ** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រសម្តេចព្រះមហាក្សត្រីជាអម្ចាស់ សូមព្រះអង្គអនុមោទនានូវមហាកុសល ដោយព្រះរាជហឫទ័យជ្រះថ្លាដ៏ខ្ពង់ខ្ពស់បំផុត ។ សូមឧទ្ទិសចំពោះបារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ដែលបានត្រាស់ដឹងកន្លងមកក្នុងលោក ហើយនឹងត្រាស់ក្នុងអនាគត និងដោយតេជានុភាពគុណបុណ្យព្រះរតនត្រៃ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់*

ព្រះអង្គ ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលរក្សា **សម្តេចព្រះមហាក្សត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ពោធិព្រឹក្សដ៏ត្រជាក់ដល់ប្រជានុរាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូម **ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ
ថ្ងៃពុធ ៩ កើត ខែមាឃ ឆ្នាំ វក អដ្ឋស័ក ព.ស. ២៥៦០

**កុល ផេង**
ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា
នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

# សូមគោរពជូនមហាកុសល
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់

*តាងនាមសមាជិកសមាជិកាពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់និងភរិយាព្រមទាំងបុត្រសូមលំឱនកាយគោរពជូន សព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ចំពោះ* **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូននូវមហាកុសល ដែលយើងខ្ញុំបានប្រែសម្រួលនិងរៀបរៀងនូវសៀវភៅ* **សុវណ្ណសាមជាតកពិស្តារ** *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ សូម* **សម្តេចទាំងពីរ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះដោយសទ្ធាជ្រះថ្លា ។ សូមគុណបុណ្យនៃព្រះរតនត្រៃ និងបារមីនៃវត្ថុសក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សា និង ប្រសិទ្ធពរជ័យជូន* **សម្តេចតេជោ** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ព្រមទាំង* **បុត្រាបុត្រី** *និង* **ចៅៗ** *ជាទីស្រឡាញ់របស់សម្តេច  សូមប្រកបដោយជន្មាយុយឺនយូរ សុខភាពល្អបរិបូណ៌*

បញ្ញាញាណវាងវៃ ដើម្បីដឹកនាំប្រទេសជាតិក្នុងការពង្រឹងសុខសន្តិភាព និងការអភិវឌ្ឍឲ្យបានរុងរឿងដ៏បរិបូណ៌តទៅអនាគត ។

ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្ត នូវវីរភាពនិងវិរិយភាពដ៏អង់អាចរបស់ **សម្តេច** ដែលបានបំពេញនូវបេសកកម្មដ៏លំបាក ក្នុងការស្វែងរកសេចក្តីសុខសន្តិភាពជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍព្រះរាជាណាចក្រកម្ពុជាយើង ដរាបរៀងមក ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខ មហាប្រសើរ ព្រមទាំងទទួលបាននូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ

ថ្ងៃពុធ ៩ កើត ខែមាឃ ឆ្នាំ វក អដ្ឋស័ក ព.ស. ២៥៦០

**កុល ផេង**

ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

# បុព្វកថា

*សុវណ្ណសាមជាតក ជាដំណើររឿងតំណាលពីបុព្វជាតិរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ កាលដែលព្រះអង្គយោនយកកំណើតជាសុវណ្ណសាម មានកតញ្ញូកតវេទិតាធម៌ដ៏កំពូល បានបម្រើបារិកាតាបសិនីនិងទុកូលតាបស ជាម្ដាយឪពុកដែលពិការភ្នែកទាំងពីរនាក់ ។*

*ខ្លឹមសារចម្បងនៃទសបារមីក្នុងរឿងព្រះមហាសត្វ (សុវណ្ណសាម) នេះ គឺ ព្រះមហាសត្វបានបំពេញមេត្តាបារមីចំពោះមាតាបិតា និងសត្វទូទៅ នៅតាមដងស្ទឹងមិគសម្មតា ព្រមទាំងព្រះបាទបីឡិយក្សរាជា ។ ដោយមេត្តាមហាសាលនេះហើយ ដែលបណ្ដាលឱ្យសត្វតូចធំ យក្ស គន្ធព្វ ព្រមទាំងទេវតាក្នុងព្រៃទាំងអស់ ស្រឡាញ់រាប់អានមហាសត្វជាមិត្តសំឡាញ់ ហើយដោយតេជានុភាពនៃមេត្តាបារមីដែលមហាសត្វបានបំពេញនេះ ទើបព្រះអង្គបានរួចផុតពីគ្រោះថ្នាក់ដល់មរណៈនៃព្រួញពិសពុលរបស់ព្រះបាទបីឡិយក្សរាជា ព្រមទាំងបានញ៉ាំងឱ្យភ្នែករបស់មាតាបិតាព្រះអង្គជាសះស្បើយ ភ្លឺឡើងវិញផង ។*

*រឿងជាតកនេះ ពុទ្ធសាសនិកខ្មែរយើង សឹងតែបានជ្រាបគ្រប់ៗគ្នាមកហើយ តាមរយៈការស្ដាប់ធម្មកថិក សម្ដែងមហាជាតក ការស្មូត្រ និងការអានសៀវភៅ ។ រីឯសិស្សសាលាកម្រិតមធ្យមរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏បានយល់ដឹងរឿងសុវណ្ណសាមនេះ តាមសៀវភៅទសជាតកសង្ខេប ដែលរៀបរៀងដោយបណ្ឌិត ឈឹម ស៊ុម ក្នុងព.ស. ២៥០២, គ.ស. ១៩៥៩ ដែរ ។*

សាកលវិទ្យាល័យបញ្ញាសាស្ត្រ បានសម្រេចចិត្តបកប្រែរឿងសុវណ្ណ-សាមជាតកពិស្តារនេះពីអដ្ឋកថាភាសាបាលីជាថ្មីម្តងទៀត ។ វិធីសាស្ត្រក្នុងការបកប្រែ ពុំបានលើកយកមេពាក្យបាលីក្នុងគាថាមកដាក់ហើយទើបប្រែពន្យល់នោះទេ គឺប្រែយកសេចក្តីទាំងក្នុងបាលីគាថា ទាំងក្នុងសេចក្តីអធិប្បាយនៃអដ្ឋកថាឲ្យចេញជាភាសាខ្មែរល្មមស្តាប់បានតែម្តង ។

គោលបំណងនៃការបកប្រែរៀបរៀងព្រះសុវណ្ណសាមពិស្តារនេះ គឺដើម្បី៖

១- ជាជំនួយក្នុងកម្មវិធីអប់រំជាតិ កម្រិតមធ្យមនិងឧត្តមសិក្សា

២- ជាឯកសារសិក្សាស្រាវជ្រាវសម្រាប់ពុទ្ធសាសនិកជនទូទៅ

៣- ជាការអភិរក្សផ្សព្វផ្សាយអក្សរសិល្ប៍តាមបែបព្រះពុទ្ធសាសនា

៤- ជាកេរមរតកតម្កល់ទុកសម្រាប់កុលបុត្រកុលធីតាជំនាន់ក្រោយ

៥- ជាការផ្សព្វផ្សាយព្រះពុទ្ធសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យរីតតែបានទូលំទូលាយ សម្រាប់ពលរដ្ឋទូទៅ ។

ព្រះសុវណ្ណសាមជាតកពិស្តារនេះ ទោះបីក្រុមជំនុំបានត្រួតពិនិត្យលើខ្លឹមសារ ន័យសេចក្តី អក្ខរៈ ឃ្លាល្បះ ដោយយកចិត្តទុកដាក់និងប្រុងប្រយ័ត្នយ៉ាងណាក្តី ក៏គង់នៅមានសល់សេចក្តីខុសឆ្គងខ្វះជាពុំខាន ។

យើងខ្ញុំសូមអភ័យទោសអំពីសម្នាក់លោកអ្នកប្រាជ្ញ កវីបណ្ឌិតព្រឹទ្ធាចារ្យ និងលោកអ្នកអានជាទីគោរពទាំងអស់ ដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់ បើមានការផ្តាំផ្តែង ឬខ្វះខាតដោយអចេតនា ។ ត្រង់ចំណុចនេះ

យើងខ្ញុំបានទឹកឃើញនូវចំណាររបស់សម្ដេច ព្រះមហាសុមេធាធិបតី **ជួន ណាត ជោតញ្ញាណោ** មួយប្រយោគថា ៖

"ធម្មតា ការងារអ្វីទាំងអស់ក្នុងលោក តែងតែមានភ្លាំងភ្លាត់ខ្លះ បើមិនច្រើន ក៏តិចតួចពុំខាន នេះជាទម្លាប់នៃការងាររបស់បុថុជ្ជន ព្រោះត្រូវជាគូគ្នានឹងខុស ប៉ុន្ដែបើមានត្រូវច្រើន មានខុសតែបន្ដិចបន្ដួច ក៏គង់អាចប្រើការកើតគ្រាន់បើជាងគ្មានសោះទៅដែរ" ។

ជាទីអវសាននៃបុព្វកថានេះ ដោយតេជានុភាពនៃកុសលដែលកើតពីការខិតខំប្រឹងប្រែងឲ្យបានចេញជាស្នាដៃដ៏ប្រពៃនេះ យើងខ្ញុំទាំងអស់គ្នាសូមឧទ្ទិសនូវផដ្ឋមនុញ្ញផល ជូនចំពោះបុព្វបុរសខ្មែរ មាតាបិតា ជីដូនជីតា បងប្អូន និងញាតិសាច់សាលោហិតទាំងអស់ក្នុងសង្សារវដ្ដ ទាំងអតីតៈ បច្ចុប្បន្ន និងអនាគត សូមឲ្យមានសុខភាពល្អ អាយុយឺនយូរ កម្លាំងកាយមាំមួន ប្រាជ្ញាវាងវៃ កុំបីមានជំងឺតម្កាត់អ្វីតិចតួច មកបៀតបៀនយាយីធ្វើទុក្ខបុកម្នេញឲ្យដល់សេចក្ដីលំបាកតិចតួចឡើយ និងសូមបានជាឧបនិស្ស័យកំពូល គឺការរួចផុតចាកវដ្ដទុក្ខដល់នូវបរមសុខ ពោលគឺព្រះនិព្វាន កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញថ្ងៃទី          ខែមករា ព.ស. ២៥៦០

**ភុល ផេង**

ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

## ជំពូកទី១

### ត្រកូលសេដ្ឋីក្រុងសាវត្ថី


សេដ្ឋីមានកូនតែមួយ ........................................................... ១
សេដ្ឋីបុត្រសាងផ្នួស ........................................................... ៤
សេដ្ឋីធ្លាក់ខ្លួនក្រ ........................................................... ៦
ភិក្ខុសេដ្ឋីបុត្រជួបញោម ........................................................... ១១
ភិក្ខុសេដ្ឋីបុត្រផ្គត់ផ្គង់ញោមស្រីប្រុស ........................................................... ១៣
ព្រះសាស្ដាសរសើរភិក្ខុចិញ្ចឹមម្ដាយឪពុក ........................................................... ១៤


## ជំពូកទី២

### កំណើតព្រះសុវណ្ណសាម


ទុកូលកុមារនិងនាងបារិកា ........................................................... ១៨
បារិកានិងទុកូលទៅសាងផ្នួស ........................................................... ២១
ភពសក្កទេវរាជឡើងកម្ដៅ ........................................................... ២២
ព្រះមហាសត្តចាប់បដិសន្ធិ ........................................................... ២៤
ម្ដាយឪពុកពោធិសត្វពិការភ្នែក ........................................................... ២៧
កំណត់សម្គាល់ ........................................................... ២៨
សុវណ្ណសាមបម្រើម្ដាយឪពុក ........................................................... ២៩

## ជំពូកទី៣

### ស្តេចបីឡិយក្សជួបសុវណ្ណសាម


ស្តេចបីឡិយក្សបាញ់សុវណ្ណសាម ..... ៣៤
ទំនួញសុវណ្ណសាម ..... ៣៧
ស្តេចបីឡិយក្សជានាបម្រើម្តាយឪពុកសុវណ្ណសាម ..... ៤៤
កំណាត់សម្គាល់ ..... ៥៣
ទេពធីតាពហុសុន្ទរី ..... ៥៦
ស្តេចបីឡិយក្សយកទឹកជូនម្តាយឪពុកសុវណ្ណសាម ..... ៥៨
ម្តាយឪពុកសុវណ្ណសាមតាំងសច្ចាធិដ្ឋាន ..... ៧០
ជនទាំង ៣ ធ្វើសច្ចាធិដ្ឋាន ..... ៧៦
សុវណ្ណសាមដឹងស្មារតីឡើងវិញ ..... ៨០
សុវណ្ណសាមថ្វាយរាជធម៌ ..... ៨៤
ព្រះសាស្តាប្រជុំជាតក ..... ៨៩

# ជំពូកទី១

## ត្រកូលសេដ្ឋីក្រុងសាវត្ថី

### និទានខាងដើម

*កាលព្រះបរមសាស្តា គង់នៅក្នុងវត្តជេតពន ទ្រង់បានប្រារព្ធភិក្ខុ ១ អង្គ ដែលជាអ្នកចិញ្ចឹមម្តាយឪពុក ហើយទ្រង់ត្រាស់សម្តែងនូវធម្មទេសនានេះ ដោយផ្តើមពាក្យបាលីជាអាទិ៍ថា «កោ នុ មំ ឧសុនា វិជ្ឈតិ» ។*

### សេដ្ឋីមានកូនតែមួយ

*មានរឿងតំណាលថា ក្នុងក្រុងសាវត្ថី មានត្រកូលសេដ្ឋីមួយ មានទ្រព្យចំនួន ១៨ កោដិ, និងមានកូនប្រុសតែម្នាក់ ។ សេដ្ឋីបុត្រនោះ ជាទីស្រឡាញ់ពេញចិត្តរបស់ម្តាយឪពុកខ្លាំងណាស់ ។ ក្នុងថ្ងៃមួយ សេដ្ឋីបុត្រនោះ នៅលើប្រាសាទដ៏មានក្បូរក្បាច់រចនាល្អ វិចិត្រឆើតឆាយបើកសីហបញ្ជរ[១] ចោលភ្នែកក្រឡេកមើលទៅតាមដងវិថី ក៏ឃើញពពួកជន*

---

*[១] បង្អួចរបស់អ្នកមានអានុភាពដូចសីហៈ គឺបង្អួចដំណាក់ឬប្រាសាទរបស់ក្សត្រិយ៍ ទ្រង់រាជ្យ : ព្រះរាជាទ្រង់ប្រថាប់ក្បែរសីហបញ្ជរ ។ ឬ បង្អួចមានរង្វង់ដូចជាទ្រង់ជំហរសីហៈ ។*

មីរដេរដាសច្រើនកុះករ មានដៃកាន់នូវគ្រឿងក្រអូបនិងផ្កាកម្រងជាដើម កំពុងដើរដង្ហែគ្នាឆ្ពោះទៅកាន់វត្តជេតពន ដើម្បីបានស្តាប់ព្រះធម៌ ។ សេដ្ឋីបុត្រនោះបានថ្វាយបង្គំម្តាយឪពុក សុំសេចក្តីអនុញ្ញាតទៅស្តាប់ព្រះធម៌ជាមួយនឹងមហាជនដែរ ។ ក្រោយពេលបានសេចក្តីអនុញ្ញាតហើយ សេដ្ឋីបុត្របាននាំអ្នកបម្រើឲ្យជួយកាន់គ្រឿងក្រអូបនិងផ្កាកម្រងជាដើម ធ្វើដំណើរទៅវត្ត លុះដល់ហើយគាត់ប្រាប់ឲ្យគេប្រគេននូវសំពត់, ភេសជ្ជៈ និងទឹកបាន[២] ជាដើម ចំពោះភិក្ខុសង្ឃ; រីឯខ្លួនគាត់ផ្ទាល់ បានបូជាព្រះមានព្រះភាគ ដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម រួចជាស្រេចហើយ បានអង្គុយក្នុងទីដ៏សមគួរ ស្តាប់នូវព្រះធម៌ ។ លុះផ្តោតចិត្តស្តាប់តាមក្រសែព្រះធម៌ទៅ ចិត្តរបស់គាត់យល់ជាក់នូវ

---

[២] ទឹក ៨ ប្រភេទ ដែលបព្វជិតពុទ្ធសាសនិកគួរឆាន់ក្នុងវេលាវិកាលបាន គឺទឹកដែលធ្វើដោយផ្លែស្វាយ, --ដោយផ្លែព្រីង, --ដោយផ្លែចេកមានគ្រាប់, --ដោយផ្លែចេកឥតគ្រាប់, --ដោយផ្លែស្រគំ, --ដោយផ្លែច័ន, --ដោយមើមឬឫសនៃជលជាតិមានក្រឪឈូកជាដើម, --ដោយផ្លែមាក់ប្រាង ។ មាន ៨ ប្រភេទដទៃទៀតគឺទឹកដែលធ្វើដោយផ្លែសង្វ៉ារ, --ដោយផ្លែពុទ្រាតូច, --ដោយផ្លែពុទ្រាធំ, --ដោយទឹកដោះគោរាវ, --ដោយប្រេងល្ងជាដើម, --ដោយទឹកដោះស្រស់, --ដោយទឹកបបរ, --ដោយរសជាតិនៃវត្ថុស្រស់ពួកខ្លះមានបន្លែជាដើម (សម្រាប់បព្វជិតមានជំងឺ)។ ហៅចំពោះឈ្មោះមួយៗ ឬហៅត្រឹមតែ *ទឹកបាន* ប៉ុណ្ណោះក៏បាន ។

ទោសក្នុងកាមទាំងឡាយ និងកត់សម្គាល់ឃើញនូវអានិសង្សក្នុងការចេញចាកកាមទៅសាងផ្នួស ។ ពេលបរិស័ទក្រោកចេញទៅអស់, សេដ្ឋីបុត្រក្រាបទូលសុំសាងផ្នួស ចំពោះព្រះមានព្រះភាគ លុះបានឮទំនៀមព្រះតថាគតមិនដែលបំបួសសេដ្ឋីបុត្រណា ដោយពុំមានការអនុញ្ញាតពីមាតាបិតា ដូច្នោះហើយទើបសេដ្ឋីបុត្រក្រាបថ្វាយបង្គំលាព្រះមានព្រះភាគ ត្រឡប់ទៅគេហដ្ឋានវិញ ។ ដល់ហើយ សេដ្ឋីបុត្រក្រាបថ្វាយបង្គំម្ដាយឪពុកដោយសេចក្ដីគោរពតាមទម្លាប់របស់ខ្លួន ហើយក៏សុំសេចក្ដីអនុញ្ញាតពីពួកគាត់យ៉ាងនេះថា ៖

"បពិត្រអ្នកម្ដាយលោកឪពុក ខ្ញុំសុំទៅបួសនៅក្នុងសម្នាក់របស់ព្រះសម្មាសម្ពុទ្ធ" ។

គ្រានោះ ម្ដាយឪពុករបស់សេដ្ឋីបុត្រ គ្រាន់តែឮពាក្យកូនសុំដូច្នោះភ្លាមពួកគាត់នឹកស្រណោះកូនខ្លោចចិត្តស្ទើរបែកទ្រូងជា ៧ ភាគ ដោយមូលហេតុថា ពួកគាត់មានកូនតែមួយ ។ ពេលនោះ ពួកគាត់អាក់អួលក្ដុកក្ដួល ញាប់ញ័រទ្រូងចំប្រប់ ព្រោះស្រឡាញ់កូនជាពន់ពេក នាំគ្នានិយាយទាំងអួលណែនទៅរកកូនថា ៖

"ហៃកូនសម្លាញ់ស្មើនឹងកែវភ្នែក, ស្មើនឹងបេះដូង, ស្មើនឹងជីវិត កូនជាអ្នកស្នងត្រកូល បើឥតពីកូនទៅ ពួកយើងនឹងរស់នៅដូច

ម្តេចកើត ? ជីវិតរបស់ពួកយើងជាប់ស្អិតនឹងកូនខ្លាំងណាស់ ។ កូនអើយ ជាក់ស្តែងហើយតើនៅពេលនេះ ម្តាយឪពុកឈានចូលដល់វ័យចំណាស់ ចាស់ជរា អាយុច្រើនណាស់ហើយ, ពួកយើងនឹងស្លាប់ក្នុងថ្ងៃនេះ ឬថ្ងៃស្អែក ឬក៏ក្នុងថ្ងៃខានស្អែកក៏ថាបាន, ហេតុដូច្នោះ កូនកុំទៅបួសចោលម្តាយឪពុកឡើយ ។ ហៃកូន, ដែលហៅថា ផ្នួស ៗ នេះ គឺគេធ្វើបានដោយកម្រក្រៃលែង ចង់ត្រជាក់បានក្តៅ ចង់ក្តៅបានត្រជាក់, ដូច្នោះ កូនកុំចេញទៅបួសឡើយណាកូន" ។

## សេដ្ឋីបុត្រសាងផ្នួស

ឮដូច្នោះ សេដ្ឋីបុត្រកើតទុក្ខទោមនស្ស ឱនក្បាល អង្គុយសញ្ចប់សញ្ចឹង មិនបរិភោគអាហារ រហូត ៧ ថ្ងៃ ។ ឃើញដូច្នោះ ម្តាយឪពុករបស់សេដ្ឋីបុត្រ ពិភាក្សាគ្នាយ៉ាងនេះថា ៖

"ប្រសិនបើយើងមិនអនុញ្ញាតទេ, គេពិតជាស្លាប់មិនខាន, យើងនឹងលែងបានឃើញគេរហូត, ប៉ុន្តែបើយើងអនុញ្ញាតឲ្យគេចេញបួសវិញ គេនៅមានជីវិតរស់, យើងអាចនឹងឃើញគេបាននៅពេលណាមួយ" ។

លុះប្រឹក្សាគ្នាដូច្នេះហើយ លោកទាំងពីរបានអនុញ្ញាតថា ៖

"ហៃកូនសម្លាញ់ ណ្ហើយចុះ ! យើងអនុញ្ញាតឲ្យអ្នកទៅបួស, ចូរបួសចុះកូន" ។

ព្ធដូច្នោះ សេដ្ឋីបុត្រមានចិត្តត្រេកអរសប្បាយយ៉ាងខ្លាំង បន្ទន់ខ្លួនប្រាណចុះ ក្រាបថ្វាយបង្គំអរគុណម្តាយឪពុក រួចដើរទៅវត្ត ក្រាបទូលសូមសាងផ្នួសចំពោះព្រះមានព្រះភាគ ។ ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុមួយអង្គមកជួបហើយបង្គាប់ថា "ចូរអ្នកបំបួសសេដ្ឋីបុត្រនេះចុះ" ។ ភិក្ខុអង្គនោះ ក៏បានបំបួសសេដ្ឋីបុត្រនោះ តាមពុទ្ធតម្រាស់ ។

តាំងពីសេដ្ឋីបុត្រនោះសាងផ្នួសមក លោកមានលាភសក្ការៈជាច្រើន និងជាអ្នកឧស្សាហ៍ធ្វើវត្តប្រណិប័តន៍ជាហេតុធ្វើឲ្យអាចារ្យនិងឧបជ្ឈាយ៍គាប់ចិត្ត លោកបានបំពេញឧបសម្បទាជាភិក្ខុ និងរៀនសូធ្យធម្មបរិយត្តិក្នុងសម្នាក់អាចារ្យនិងឧបជ្ឈាយ៍អស់ ៥ វស្សាថែមទៀត ។ ភិក្ខុសេដ្ឋីបុត្រគិតថា ៖

"អញនៅទីនេះច្របូកច្របល់ណាស់ ការបួសហើយនៅរបៀបនេះ មិនសមគួរដល់អាត្មាអញសោះ"

គិតដូច្នេះហើយ លោកមានបំណងចង់បំពេញវិបស្សនាធុរៈ ក៏សុំរៀនកម្មដ្ឋានជាបន្តក្នុងសម្នាក់ឧបជ្ឈាយ៍ ចប់សព្វគ្រប់ហើយ ថ្វាយបង្គំលាឧបជ្ឈាយ៍ ចេញអំពីវត្តជេតពនទៅនៅក្នុងព្រៃ ក្បែរស្រុកចុងកាត់មាត់

*ញកមួយ ៗ ភិក្ខុសេដ្ឋីបុត្រព្យាយាមប្រឹងប្រែងចម្រើនវិបស្សនាក្នុងទីនោះយ៉ាងខ្ជាប់ខ្ជួន អស់ ១២ ឆ្នាំ, ទោះជាព្យាយាមយ៉ាងនេះក៏ដោយ ក៏មិនអាចញុាំងគុណវិសេសឲ្យកើតឡើងបាន ។*

## សេដ្ឋីធ្លាក់ខ្លួនក្រ

*ពេលវេលាចេះតែកន្លងទៅ ញោមប្រុសស្រីរបស់ភិក្ខុសេដ្ឋីបុត្រក៏ធ្លាក់ខ្លួនជាមនុស្សក្រីក្រ កម្សត់ ទុគ៌ត ពីព្រោះថា ខ្ញុំប្រុសខ្ញុំស្រីដែលនៅធ្វើស្រែធ្វើជំនួញជូនពួកគាត់ ម្នាក់ ៗ មានគំនិតខិលខូចនាំគ្នាលួចទ្រព្យរត់កៀសខ្លួនទៅនៅទីដទៃ ៗ តាមគាប់ចិត្ត ដោយមាក់ងាយថា "ក្នុងត្រកូលនេះ គ្មានកូនប្រុស ឬបងប្អូនប្រុសឯណា ដែលនៅទូទាត់យកបំណុលវិញទេ" ។ សូម្បីប្រាក់មាសជាដើមដែលមានច្រើននៅក្នុងផ្ទះក៏ត្រូវពួកទាសកម្មករជាដើម លួចវេចខ្ចប់យកទៅអស់ដែរ ។ ចំណេរកាលតមក សេដ្ឋីនិងភរិយា ក៏ក្លាយជាមនុស្សកំព្រា រកត្រឹមតែអ្នកបម្រើគ្រាន់នឹងស្រោចទឹកលាងដៃឲ្យមិនបាន ក្ររហូតដល់ថ្នាក់លក់ផ្ទះសំបែងរកលំនៅស្នាក់នៅពុំបាន ស្លៀកសំពត់ចាស់ ៗ ដើរកាន់អំបែងសុំបាយតាមមុខផ្ទះ មុខគួរឲ្យអាណិតអាសូរជាពន់ពេក ។*

*ក្នុងកាលនោះ មានភិក្ខុ ១ រូប និមន្តចេញពីវត្តជេតពនធ្វើដំណើរចូលក្នុងព្រៃតាមលំដាប់ រហូតដល់លំនៅរបស់ភិក្ខុសេដ្ឋីបុត្រនោះ ។ ភិក្ខុសេដ្ឋីបុត្រ ធ្វើវត្តប្រណិប័តន៍ទទួលភិក្ខុអាគន្តុកៈ ដែលទើបនិមន្ត*

មកពីវត្តជេតពនថ្មី ៗ នោះ ។ ពេលអាគន្តុកភិក្ខុអង្គុយ ភិក្ខុសេដ្ឋីបុត្រ សំណេះសំណាលថា ៖

"បពិត្រលោកម្ចាស់ លោកម្ចាស់និមន្តមកអំពីទីណា ?"

"ខ្ញុំព្រះករុណាមកអំពីវត្តជេតពន អាវុសោ" ភិក្ខុនោះប្រាប់ ។

ភិក្ខុសេដ្ឋីបុត្រ ក៏សួរអំពីភាពមិនមានរោគរបស់ព្រះសាស្តា និងមហា-សាវ័កជាដើម រួចក៏សាកសួរអំពីស្ថានភាពរបស់ញោមស្រីញោមប្រុសរបស់ខ្លួនថា ៖

"បពិត្រលោកម្ចាស់ សេដ្ឋីឯណោះក្នុងក្រុងសាវត្ថី
មិនមានរោគទេឬ ?"
"នែអាវុសោ, កុំសួរអំពីស្ថានភាពនៃត្រកូលនោះអី"
អាគន្តុកភិក្ខុឃាត់ ។
"មានរឿងអ្វីទៅ លោកម្ចាស់ ?" ភិក្ខុសេដ្ឋីបុត្រសួរបញ្ជាក់ ។
"ម្នាលលោកអ្នកមានអាយុ ឮថាត្រកូលនោះ មានកូនប្រុសម្នាក់ កូនប្រុសនោះ ចូលបួសក្នុងព្រះពុទ្ធសាសនាហើយ, តាំងពីកាលដែលគេចេញបួសមក ត្រកូលនោះចេះតែហិនហោចទ្រព្យសម្បត្តិរហូតអស់ សូម្បីតែផ្ទះក៏គ្មាននៅដែរ, ឥឡូវនេះ មានតែតាហើយនិងយាយពីរនាក់ប៉ុណ្ណោះ ដើរសុំទានតាមមុខផ្ទះគេឯង ចិញ្ចឹម

ជីវិត ដល់នូវក្ដីលំបាក តោកយ៉ាក គួរឲ្យអាណិតអាសូរជាពន់ពេក" ។

ភិក្ខុសេដ្ឋីបុត្រ គ្រាន់តែឮពាក្យរៀបរាប់របស់អាគន្ដុកភិក្ខុនោះភ្លាម លោកពុំអាចទប់ចិត្តឲ្យតាំងនៅតាមប្រក្រតីបាន ទឹកភ្នែកក៏ហូរស្រក់អួលដើមក រកកល់ស្រែកទ្រហោយំ ។

អាគន្ដុកភិក្ខុសួរថា ៖

"អាវុសោ ថ្វីក៏អ្នកយំ ?"

ភិក្ខុសេដ្ឋីបុត្រប្រាប់ថា ៖

"បពិត្រលោកម្ចាស់, តានិងយាយទាំងនុ៎ះ ត្រូវជាញោមបង្កើតរបស់ខ្ញុំព្រះករុណា, ខ្ញុំព្រះករុណាជាកូនរបស់លោកទាំងពីរ" ។

អាគន្ដុកភិក្ខុពោលថា ៖

"ម្នាលអាវុសោ, ញោមស្រីញោមប្រុសរបស់លោកដល់ក្ដីវិនាសដូច្នេះ ដោយសារតែលោក, ចូរលោកត្រឡប់ទៅផ្គត់ផ្គង់គាត់ទាំងពីរចុះ" ។

ភិក្ខុសេដ្ឋីបុត្រគិតថា ៖

"បើទោះបីអាត្មាអញ ព្យាយាមប្រឹងប្រែងអស់ ១២ ឆ្នាំមកហើយ ក៏អញមិនអាចញ៉ាំងមគ្គផល ឲ្យកើតឡើងបាន, អញប្រាកដជាមនុស្សអកព្វដោយពិត, ផ្នួសនឹងមានប្រយោជន៍អ្វីដល់អញទៀត, អញនឹងសឹកទៅជាគ្រហស្ថចិញ្ចឹមម្ដាយឪពុក ធ្វើទាន នឹងមានឋានសួគ៌ជាខាងមុខទៅចុះ"

គិតដូច្នេះហើយ ភិក្ខុសេដ្ឋីបុត្របានរៀបចំកុដិរបស់ខ្លួនក្នុងព្រៃនោះ ប្រគេនចំពោះអាគន្តុកភិក្ខុ ។ លុះព្រឹកស្អែកឡើង លោកបានចេញអំពីព្រៃដើរទៅតាមលំដាប់ដល់វត្តមួយនៅក្រោយវត្តជេតពន ដែលនៅមិនឆ្ងាយអំពីក្រុងសាវត្ថី ។ វត្តនោះមានផ្លូវបែកជាពីរ ផ្លូវមួយទៅចំវត្តជេតពន, ផ្លូវមួយទៅចំក្រុងសាវត្ថី ។ ភិក្ខុសេដ្ឋីបុត្រឈប់ឈរនៅទ្រឹងជញ្ជឹងក្នុងចិត្តនៅទីនោះថា ៖

"តើអាត្មាគួរទៅជួបម្ដាយឪពុកមុន ឬទៅជួបព្រះទសពលមុន ?" គិតមួយស្របក់ លោកយល់ថា ៖

"អញធ្លាប់ឃើញម្ដាយឪពុកយូរហើយ, ប៉ុន្តែពីថ្ងៃនេះទៅ អញកម្រនឹងមានពេលបានមកគាល់ព្រះពុទ្ធទៀតណាស់, ព្រោះហេតុនោះ អាត្មាអញនឹងចូលទៅរកព្រះសម្មាសម្ពុទ្ធ ស្ដាប់ធម៌ព្រះអង្គសិន សឹមព្រឹកស្អែកឡើងទៅជួបម្ដាយឪពុកចុះ"

គិតដូច្នេះរួច លោកងាកមុខចេញពីផ្លូវទៅចំក្រុងសាវត្ថី បែរមកដើរផ្លូវទៅចំវត្តជេតពនវិញ ក្នុងវេលាល្ងាច ។ ក្នុងវេលាជិតភ្លឺថ្ងៃនោះ ព្រះសាស្តាបរមគ្រូនៃយើងប្រមើលមើលសត្វលោក ក៏បានឃើញនូវការដល់ព្រមនៃឧបនិស្ស័យសម្រេចនូវគុណធម៌របស់ភិក្ខុសេដ្ឋីបុត្រនេះ ។ លុះដល់ពេលភិក្ខុសេដ្ឋីបុត្រមកដល់ ព្រះសាស្តាបានសម្តែងពណ៌នាអំពីគុណរបស់ម្តាយឪពុកជាច្រើន តាមមាតុបោសកសូត្រ[៣] ។ ចំណែកភិក្ខុសេដ្ឋីបុត្រនោះ ឈរនៅចុងក្រោយបរិស័ទ ស្តាប់នូវព្រះធម៌របស់ព្រះសាស្តា គិតគ្នាន់គ្នេរក្នុងចិត្តថា ៖

> "អញស្មានថាទាល់តែសឹកទៅជាគ្រហស្ថ ទើបអាចផ្គត់ផ្គង់ម្តាយឪពុកបាន, ប៉ុន្តែព្រះសាស្តាត្រាស់ថា សូម្បីបព្វជិតក៏អាចផ្គត់ផ្គង់ម្តាយឪពុកបានដែរ, បើកុំតែអាត្មាអញមកគាល់ព្រះសាស្តាមុនទេ ម្ល៉េះសមអាត្មាអញនឹងត្រូវបាត់បង់ភេទផ្នួសនេះពុំខាន, ឥឡូវនេះអញមិនចាំបាច់សឹកទៅជាគ្រហស្ថទេ សុខចិត្តនៅជាបព្វជិតចិញ្ចឹមម្តាយឪពុកវិញ" ។

---

[៣] សូត្រដែលសម្តែងអំពីការប្រណិប័តន៍ដែលព្រះពោធិសត្វលោកទំនុកបម្រុងបម្រើម្តាយឪពុកដោយកិច្ចការសព្វសារពើ ។

## ភិក្ខុសេដ្ឋីបុត្រជួបញោម

*ភិក្ខុសេដ្ឋីបុត្រនោះ ទៅកាន់រោងស្លាក ចាប់ស្លាកភត្ត[៤]និងស្លាកយាគូ[៥] ហាក់ដូចជាភិក្ខុនៅក្នុងព្រៃ ១២ ឆ្នាំ ត្រូវអាបត្តិបារាជិក ។ ពេលព្រឹក ព្រហាមឡើង លោកចូលទៅក្នុងក្រុងសាវត្ថី គិតថា ៖*

*"តើអាត្មាអញនឹងទទួលបបរជាមុន ឬទៅជួបញោមស្រីញោមប្រុសមុន?" ក៏នឹកឃើញថា "មិនគួរទាល់តែសោះដែលអាត្មាអញទៅកាន់សម្នាក់ញោមស្រីប្រុសដោយដៃទទេ" ។*

*គិតដូច្នេះហើយ លោកក៏ត្រាច់បិណ្ឌបាតបានបបរ រួចក៏និមន្តសំដៅទៅទ្វារផ្ទះចាស់របស់ញោមស្រីប្រុស ។ គ្រានោះ ញោមស្រីប្រុសរបស់លោក កំពុងតែនៅក្បែរជញ្ជាំងផ្ទះអ្នកដទៃ សុំបបរគេហូប ។ ភិក្ខុសេដ្ឋីបុត្រនិមន្តដើរចូលទៅ ឃើញភ្លាមស្គាល់ច្បាស់ថាជាញោមស្រីប្រុសរបស់ខ្លួន ដែលកំពុងអង្គុយយ៉ាងកម្សត់ដូច្នោះ លោកក៏ឈរទ្រឹងខ្លួនជិតញោមប្រុសស្រី កើតក្តីសោកសៅ ក្តុកក្តួល អួលណែន មានទឹកនេត្ររលីងរលោង ហាមាត់និយាយអ្វីមិនចេញ ។ ញោមស្រីប្រុស ទោះ*

---

*[៤] ភត្តដែលទាយកប្រគេនភិក្ខុសង្ឃតាមស្លាក ដែលខ្លួនចាប់ត្រូវត្រង់នាមរបស់លោក : ទាយកច្រើនប្រជុំគ្នា ធ្វើសលាកភត្តក្នុងរដូវដើមឆ្នាំ ។*

*[៥] បបរដែលទាយកប្រគេនភិក្ខុសង្ឃតាមស្លាកដែលខ្លួនចាប់ត្រូវត្រង់នាមរបស់លោក ឧទាហរណ៍ ទាយកច្រើនប្រជុំគ្នាធ្វើសលាកយាគូក្នុងពេលព្រឹក ។*

បីឃើញលោកដូច្នោះ ក៏ចំណាំពុំបាន ។ គ្រានោះ ញោមស្រីសម្គាល់ត្រឹមតែថា "ភិក្ខុកំពុងឈរបិណ្ឌបាត" ហើយនិយាយនឹងលោកកូនដែលកំពុងឈរទ្រើងនោះថា ៖

"បពិត្រលោកម្ចាស់ដ៏ចម្រើន, ខ្ញុំព្រះករុណាទាំងពីរនាក់ពុំមានវត្ថុដែលគួរនឹងប្រគេនចំពោះលោកម្ចាស់ទេ, សូមលោកម្ចាស់និមន្តប្រោសសត្វទៅខាងមុខទៀតចុះ" ។

ភិក្ខុសេដ្ឋីបុត្រ លោតែឮញោមស្រីមានប្រសាសន៍ដូច្នោះភ្លាម បេះដូងរបស់លោក កាន់តែចុកណែន សៅហ្មង ញ័រចំប្រ៉ប់ និយាយអ្វីមិនចេញបានត្រឹមតែឈរសម្រក់ទឹកភ្នែកនៅចំពោះមុខញោមទាំងពីរប៉ុណ្ណោះ។ បន្ទាប់មក ញោមប្រុសរបស់លោកនិយាយនឹងញោមស្រីថា ៖

"ទៅមើលឲ្យជាក់មើល៍ យាយ ! ក្រែងលោនុ៎ះគឺជាលោកកូនរបស់យើង" ។

ឮដូច្នោះ ញោមស្រីក្រោកឡើងដើរចូលទៅជិត គយគន់មើលទៅ ក៏ចំណាំបានថាជាលោកកូនរបស់ខ្លួន ក៏ក្រាបខ្លួនដល់ដីទៀបព្រះបាទាលោកកូន យំខ្សឹកខ្សួល អណ្ដឹតអណ្ដក, រីឯញោមប្រុសលោកក៏យំខ្សឹកខ្សួលដែរ, ជនទាំង ៣ រូប មុខគួរឲ្យអាណិតអាសូរជាពន់ពេក ។

## ភិក្ខុសេដ្ឋីបុត្រផ្គត់ផ្គង់ញោមស្រីប្រុស

ចំណែកភិក្ខុសេដ្ឋីបុត្រ ជួបញោមស្រីប្រុសហើយ លោកពុំអាចទប់ស្មារតីឲ្យរឹងមាំបាន ទឹកភ្នែកចេះតែហូរមិនបាត់ ។ បន្ទាប់ពីបានរំសាយសេចក្ដីសោកសៅ ភិក្ខុសេដ្ឋីបុត្រលួងលោមញោមស្រីប្រុសថា៖

"ញោមទាំងពីរសូមកុំព្រួយឡើយ, អាត្មាភាពនឹងចិញ្ចឹមញោម

មិនឲ្យញោមលំបាកដូច្នេះទៀតឡើយ" ។

ដូច្នេះហើយ លោកឲ្យញោមស្រីប្រុសបរិភោគបបរ អញ្ជើញគាត់ទាំងពីរឲ្យអង្គុយក្នុងទីដ៏សមគួរ លោកត្រឡប់ទៅបិណ្ឌបាតបាយមួយសាទៀត យកមកជូនញោមបរិភោគ ត្រឡប់ទៅមួយសាទៀត ស្វែងរកបិណ្ឌចង្ហាន់សម្រាប់ឆាន់ខ្លួនឯង ទើបលោកនិមន្តទៅកាន់សម្នាក់ញោមវិញ អញ្ជើញញោមបរិភោគអាហារមុនម្ដងទៀត ទើបបានឆាន់ខ្លួនឯង ក្នុងកាលជាខាងក្រោយ ។ តាំងអំពីកាលនោះមក ភិក្ខុសេដ្ឋីបុត្រតែងតែទំនុកបម្រុងញោមស្រីប្រុស ដោយរបៀបនេះ ជារៀងរហូត ។ ចង្ហាន់ជាដើម ដែលទាយកទាយិកាប្រគេនរៀងរាល់ថ្ងៃពេញបូណ៌មី ឬ ថ្ងៃ ១៥ រោច លោកទទួលហើយ តែងយកទៅជូនញោមទាំងពីរ ខ្លួនឯងសុខចិត្តត្រាច់បិណ្ឌបាត, ចួនបាន ក៏ឆាន់ ចួនមិនបាន ក៏អត់ ។ សូម្បីតែសំពត់ស្បៀកដ្ឋតទឹកផ្សេង ៗ បន្តិចបន្តួច ក៏លោកយកទៅជូនញោមស្រីប្រុសដែរ ។ ក្រណាត់ចាស់ ៗ ដែលសល់ពីញោមស្រីប្រុស

*ប្រើ លោកតែងយកទៅដេរប៉ះ រួចជ្រលក់ប្រើប្រាស់ដោយខ្លួនឯង ។ ថ្ងៃដែលឥតបានចង្ហាន់ ច្រើនជាងថ្ងៃដែលបាន ។ ក្នុងសភាពនឿយហត់ក្នុងការបម្រើញោមទាំងពីរ ស្បង់និងចីវរភិក្ខុសេដ្ឋីបុត្រ មើលទៅសៅហ្មងជាខ្លាំង ។*

## ព្រះសាស្តាសរសើរតិក្ខុចិញ្ចឹមម្តាយឪពុក

*កាលដែលភិក្ខុសេដ្ឋីបុត្រទំនុកបម្រុងញោមស្រីប្រុសយ៉ាងនេះគ្រាក្រោយមក លោកក៏ធ្លាក់ខ្លួនស្គមចេញសរសៃរវាម[៦] ពាសពេញប្រាណ សម្បុរលឿងស្លេកស្លាំង ។ គ្រានោះ ភិក្ខុទាំងឡាយជាសន្ទិដ្ឋមិត្រ[៧] និងសម្ភត្តមិត្រ[៨] សួរភិក្ខុសេដ្ឋីបុត្រថា ៖*

---

[៦] (គុ.) *ដែលចេញលំនាំក្រវាម ៗ ឬលេចថ្ពោល ៗ ឡើងរសេមរសាម : ស្គាមរវាម, សរសៃរវាម ។ កិ. វិ. ដែលវារ, លូន ឬដើររសេមរសាម : ជន្ទេនវាររវាម, ពស់លូនរវាម, ក្មេងដើររវាម ។*

[៧] (ន.) (បា.),(សំ.) *(សន់-ទិត-ឋៈមិត) (សំទ្ឫ្ដ + មិត្រ)* មិត្តដែលគ្រាន់តែបានចួបឃើញគ្នាមួយដងមួយកាលមិនសូវស្និទ្ធស្នាលប៉ុន្មាន, មនុស្សស្គាល់គ្នា : *លុះខ្ញុំទៅដល់ទីនុះមានពួកសន្ទិដ្ឋមិត្ត និង សម្ភត្តមិត្តមកទទួលឈូឆរអេបអរសាទរ ។ ព. ផ្ទ. សម្ភត្តមិត្ត, អទិដ្ឋមិត្ត ឬ--មិត្រ ។*

[៨] (ន.) (បា.),(សំ.) *(ស័ម-ភ័ត-តៈមិត) (សម្ភត្ត; សំភត្ត ឬ សម្ភក្ត)* មិត្តជិតដិតទុកចិត្តស្និទ្ធស្នាលយ៉ាងមាំ (ទទ្ឈមិត្ត) : *អ្នកនុះជាសម្ភត្តមិត្តរបស់ខ្ញុំ ។ ព. ផ្ទ. សន្ទិដ្ឋមិត្ត ។*

> "ម្នាលអាវុសោ, ដើមឡើយ ពណ៌សម្បុរនៃសរីរកាយរបស់លោក ស្អាតផូរផង់, ចុះឥឡូវនេះម្ដេចក៏លោកស្គាំងស្គម លឿងស្លេក ស្លាំង ចេញសរសៃរវាមម្ល៉េះ ? អាវុសោឯងកើតអាពាធឬ ?"

ភិក្ខុសេដ្ឋីបុត្រឆ្លើយថា ៖

> "ទេ អាវុសោ, ខ្ញុំព្រះករុណាមិនមានអាពាធទេ, ប៉ុន្តែថា ខ្ញុំព្រះករុណាមានបលិពោធ[៩]" ។

រួចលោកបន្តរៀបរាប់នូវប្រវត្តិការណ៍ទំនុកបម្រុងញោមទាំងពីរនោះ ។ លំដាប់នោះ ភិក្ខុទាំងឡាយនិយាយនឹងភិក្ខុសេដ្ឋីបុត្រថា ៖

> "ម្នាលអាវុសោ, ព្រះមានព្រះភាគហាមយើងមិនឲ្យញុំាំងទាន ដែលទាយកឲ្យដោយសទ្ធាធ្លាក់ចុះឡើយ, ប៉ុន្តែលោកយកទាន ដែលទាយកឲ្យដោយសទ្ធាទៅផ្គត់ផ្គង់គ្រហស្ថដូច្នេះ ឈ្មោះថា ធ្វើនូវអំពើមិនគប្បី" ។

---

[៩] (ន.) (បា.) (ប៉ៈ លិ ពោធ) សេចក្ដីខ្វល់, សេចក្ដីរវល់ក្នុងកិច្ចការណាមួយ ដែលធ្វើឲ្យខ្វល់ចិត្ត ។ បលិពោធនេះនៅក្នុងកឋិនកម្មមាន ២ គឺៈ អាវាសបលិពោធ (កង្វល់ចំពោះអាវាស), ចីវរបលិពោធ (កង្វល់ចំពោះចីវរ). ឧ. ភិក្ខុនៅមានបលិពោធក្នុងអាវាស, មាតាបិតាមានបលិពោធចំពោះបុត្រធីតា ធ្វើឲ្យគាត់មានកង្វល់រកតែទៅសមាទានសីលមិនកើត ។

ភិក្ខុសេដ្ឋីបុត្រ ស្តាប់សម្តីរបស់ពួកភិក្ខុជាមិត្រហើយ លោកអៀនខ្មាស ក្រាញខ្លួនមិនហ៊ានទៅណាមកណា ។ ចំណែកភិក្ខុទាំងឡាយនោះ ថាឲ្យលោកប៉ុណ្ណោះមិនស្កប់ចិត្តនាំគ្នាទៅកាន់សម្នាក់ព្រះមានព្រះភាគ ក្រាបទូលចំពោះព្រះសាស្តាថា ៖

"បពិត្រព្រះអង្គដ៏ចម្រើន មានភិក្ខុមួយអង្គឯណោះញុំាងទាន ដែលទាយកប្រគេនដោយសទ្ធាឲ្យធ្លាក់ចុះ គឺភិក្ខុអង្គនោះចិញ្ចឹម គ្រហស្ថ" ។

ព្រះសាស្តាត្រាស់ឲ្យហៅភិក្ខុរូបនោះមកចូលគាល់ ហើយសួរថា ៖

"ម្នាលភិក្ខុ បានឮថាអ្នកយកទានដែលគេឲ្យដោយសទ្ធា ទៅចិញ្ចឹមគ្រហស្ថពិតមែនឬ?"

"ពិតមែន ព្រះអង្គ" ភិក្ខុសេដ្ឋីបុត្រ ក្រាបទូល ។

ព្រះសាស្តាមានបំណងឲ្យភិក្ខុនោះពណ៌នាអំពីទង្វើរបស់ខ្លួន និងទ្រង់ មានបំណងប្រកាសសម្តែងនូវបុព្វចរិយា[១០]របស់ព្រះអង្គ ទ្រង់ក៏សួរថា ៖

---

[១០] បុប-ព:-ច:រិយ៉ា) ន. (បា.; សំ. បូវ៌ចយា) ចរិយាដើម គឺការប្រព្រឹត្ត, សំណាង ឬ មារយាទ, ទម្លាប់, សណ្តាប់ធ្នាប់, ដែលបុគ្គលធ្លាប់បានប្រព្រឹត្តពីជាតិមុនៗ មកជាប់ជាស្នាមតាមមកដល់ជាតិនេះ ។

"ម្នាលភិក្ខុ គ្រហស្ថដែលអ្នកចិញ្ចឹមនោះ ជានរណា ?"

ភិក្ខុសេដ្ឋីបុត្រក្រាបទូលថា ៖

"គ្រហស្ថនោះ ត្រូវជាញោមស្រីញោមប្រុសបង្កើតរបស់ខ្ញុំព្រះករុណា ព្រះអង្គ" ។

ព្រះសាស្ដាប្រទានសាធុការ ៣ ដងថា "សាធុ សាធុ សាធុ (ប្រពៃណាស់)" ។

ដើម្បីលើកទឹកចិត្តភិក្ខុសេដ្ឋីបុត្រឲ្យកាន់តែមានសេចក្ដីឧស្សាហ៍ ព្រះសាស្ដាទ្រង់ត្រាស់បន្តថា ៖

"អ្នកដើរតាមមាគ៌ារបស់តថាគតហើយ, សូម្បីតថាគត កាលនៅជាពោធិសត្វសាងបុព្វចរិយា ក៏ធ្លាប់ចិញ្ចឹមម្ដាយឪពុកអ៊ីចឹងដែរ" ។

ភិក្ខុសេដ្ឋីបុត្រ បានដកដង្ហើមធូរស្រួល ដោយពុទ្ធពុទ្ធតម្រាស់ដូច្នោះ ។ ភិក្ខុទាំងឡាយ ក្រាបទូលអារាធនាព្រះសាស្ដាឲ្យទ្រង់សម្ដែងបញ្ជាក់អំពីបុព្វចរិយារបស់ព្រះអង្គ ។ ព្រះសាស្ដាក៏នាំអតីតនិទានមកសម្ដែងដូចតទៅនេះ ៖

# ជំពូកទី២

## កំណើតព្រះសុវណ្ណសាម

### ទុកូលកុមារនិងនាងបារិកា

*ក្នុងកាលកន្លងបាត់ស្ងាត់យូរលង់ណាស់មកហើយ មានស្រុកអ្នកនេសាទពីរ មួយនៅត្រើយស្ទឹងខាងអាយ, មួយនៅត្រើយស្ទឹងខាងនាយ មិនឆ្ងាយប៉ុន្មានអំពីក្រុងពារាណសី ។ ក្នុងស្រុកនីមួយ ៗ មានត្រកូលនេសាទ៥០០ ៗ និងមានប្រធាននេសាទមួយនាក់ ៗ ក្នុងស្រុកនីមួយ ៗ នោះ ។ ប្រធាននេសាទទាំងពីរនាក់ បានជាសម្លាញ់នឹងគ្នាតាំងពីនៅកំលោះ ៗ បានធ្វើសេចក្ដីប្ដេជ្ញានឹងគ្នាយ៉ាងប្រាកដប្រជាថា ៖*

> *"បណ្ដាយើងទាំងពីរនាក់ បើនរណាម្នាក់បានកូនស្រី ហើយម្នាក់ទៀតបានកូនប្រុស, យើងនឹងធ្វើជន្ទងនឹងគ្នារៀបអាពាហ៍ពិពាហ៍ឲ្យកូនយើងទាំងពីរបានគ្នាជាភរិយាស្វាមី" ។*

*ចំណេរកាលតមក ប្រធានស្រុកនេសាទខាងត្រើយអាយ បានកូនប្រុសម្នាក់ ហើយដាក់ឈ្មោះថា ទុកូល[១១] ព្រោះក្នុងពេលកើតមក កូននោះគេទទួលដោយសំពត់សាច់ល្អ ។ ចំណែកខាងប្រពន្ធរបស់ប្រធាន*

---

[១១] *ឈ្មោះសំពត់មួយប្រភេទត្បាញដោយសំបកឈើ ជាសំពត់ល្អ ។*

នេសាទនៅត្រើយខាងនាយឯណោះវិញ បានកូនស្រីម្នាក់ ហើយដាក់ឈ្មោះថា **បារិកា** ព្រោះហេតុតែនាងកើតនៅខាងត្រើយនាយនៃស្ទឹង ។ កូន ៗ ទាំង ២ នោះ មានរូបស្អាតក្រៃលែង សម្បុរដូចមាស គួរជាទីជ្រះថ្លានៃចិត្តរបស់មនុស្សផងទាំងពួង ។ កូនទាំងពីរនោះ បើទុកជាកើតនៅក្នុងត្រកូលអ្នកនេសាទក៏ដោយ តែអ្នកទាំងពីរពុំបានធ្វើនូវអំពើបាណាតិបាត គឺអំពើសម្លាប់សត្វបន្តិចបន្តួចណាឡើយ ។

ចំណេរកាលក្រោយមក ពេលទុកូលកុមារគ្រប់អាយុ ១៦ ឆ្នាំ ម្ដាយឪពុកសួរចិត្តគេថា ៖

"ហៃកូនសម្លាញ់ ម្ដាយឪពុកគិតថានឹងស្ដីដណ្ដឹង
កូនក្រមុំគេមកធ្វើជាប្រពន្ធឲ្យកូនឯង" ។

ចំណែកទុកូលកុមារ ហេតុតែជាក្មេងច្យុតមកអំពីព្រហ្មលោក ខ្លួនជាសត្វបរិសុទ្ធ យកដៃខ្ទប់ត្រចៀកទាំងពីរនិយាយថា ៖

"ខ្ញុំមិនត្រូវការគ្រប់គ្រងផ្ទះទេ អ្នកម្ដាយលោកឪពុក !
សូមលោក មេត្តាកុំនិយាយពាក្យបែបនេះអី" ។

ទុកូលកុមារត្រូវម្ដាយឪពុកអង្វររហូតដល់ ៣ លើក យ៉ាងណាក៏ដោយគាត់មិនយល់ព្រមយកប្រពន្ធតាមយោបល់របស់ម្ដាយឪពុកសោះ ។ រីឯកូនក្រមុំ **បារិកា** ឯណោះវិញ នាងក៏ត្រូវម្ដាយឪពុកសួរចិត្តដែរថា ៖

"ហៃកូនស្រីសម្លាញ់, មិត្រភក្តិរបស់ម៉ែឪ គេមានកូនប្រុសរូបស្រស់សង្ហា សម្បុរមាស យើងនឹងលើកកូនឯង ឲ្យជាភរិយារបស់បុរសនោះ" ។

កូនក្រមុំបារិកា យកដៃទាំង ២ ខ្ទប់ត្រចៀកនិយាយដូចកូនកំលោះទុកូល ពីព្រោះនាងក៏ច្យុតចាកព្រហ្មលោកដែរ មិនមានចិត្តចង់បានការរស់នៅបែបឃរាវាស តាមយោបល់របស់ម្ដាយឪពុកឡើយ ។ និយាយពីទុកូល ជាកូនកំលោះឯណោះវិញ គេបានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅឲ្យកូនក្រមុំបារិកា យ៉ាងប្រញាប់ ដែលសេចក្តីក្នុងសំបុត្រនោះមានខ្លឹមសារថា ៖

"ហៃបារិកា, ប្រសិនបើនាងមានសេចក្តីប្រាថ្នាមេថុនធម្ម (ការរស់នៅបែបស្វាមីភរិយា) សូមនាងមេត្តាជ្រើសបុរសដទៃធ្វើជាស្វាមីចុះ, ចំពោះខ្ញុំ មិនមានចំណង់ក្នុងមេថុនធម្មទេ" ។

ចំណែកនាងបារិកាក៏សរសេរសំបុត្រមួយ ដែលមានលំនាំសេចក្តីដូចគ្នា ផ្ញើទៅជូនកូនកំលោះទុកូលដែរ ។

## ចារិកានិងទុកូលនៅសាងផ្នួស

*គ្រានោះ បើទុកណាជាកូនប្រុសស្រីមិនប្រាថ្នាយកគ្នាជាប្ដីប្រពន្ធក៏ដោយ ក៏អ្នកទាំងពីរបង្ខំចិត្តរៀបអាពាហ៍ពិពាហ៍បំពេញបំណងម្ដាយឪពុក ។ ក្រោយពីរៀបការ អ្នកទាំងពីរ ពិតមែនតែនៅជាមួយគ្នា ប៉ុន្តែពុំបានលិចលង់ក្នុងសមុទ្រកិលេសតណ្ហា[១២]ឡើយ មើលទៅដូចជាមហាព្រហ្មទាំងពីររូប ។ ចំណែកទុកូលមិនសម្លាប់ត្រីឬសត្វម្រឹគទេ, ដោយហោចទៅ សូម្បីសាច់ដែលនាំមកស្រាប់ ក៏គាត់ពុំដែលលក់ដូរដែរ ។ លំដាប់នោះ ម្ដាយឪពុកប្រាប់កូនថា ៖*

> *"ហៃកូន, កូនឯងកើតមកក្នុងត្រកូលនេសាទ មិនប្រាថ្នាការរស់នៅបែបឃរាវាស[១៣] មិនធ្វើអំពើសម្លាប់សត្វ, តើកូននឹងធ្វើការងារអ្វី ?"*

*កូនទាំងពីរនិយាយថា ៖*

> *"បពិត្រអ្នកម្ដាយលោកឪពុក, បើលោកអនុញ្ញាតឲ្យខ្ញុំទាំងពីរបួស ខ្ញុំទាំងពីរនាក់នឹងទៅសាងផ្នួស" ។*
>
> *"បើដូច្នោះ ចូរកូនទាំងពីរទៅបួសចុះ" ម្ដាយឪពុកអនុញ្ញាត ។*

---

*[១២] ចំណង់ក្នុងការសេពសន្ថវៈដែលកម្របំពេញឲ្យពេញ ប្រៀបដូចមហាសមុទ្រដែលមិនចេះពេញដោយទឹកស្ទឹងនិងទន្លេ ។*

[១៣] (ន.) (បា.),(សំ.) (ឃៈរា--) *(គ្ឫហាវាស) ការនៅគ្រប់គ្រងផ្ទះ; អ្នកនៅគ្រប់គ្រងផ្ទះ ។*

ទុកូលនិងបារិកា ត្រេកអររីករាយស្រស់ស្រាយពន់ពេក ក្រាបថ្វាយបង្គំលាម្តាយឪពុក ដើរចេញពីស្រុកទៅតាមឆ្នេរទន្លេគង្គាតាមលំដាប់ រហូតទៅដល់ភ្នំហិមពាន្ត ចុះពីភ្នំហិមពាន្ត ដល់ស្ទឹងគង្គា ដើរតាមនោះផុតពីស្ទឹងគង្គា ក៏បានឆ្ពោះមុខទៅរកស្ទឹង ឈ្មោះ**មិគសម្មតា** ។

## ភពសក្កទេវរាជឡើងកម្តៅ

ក្នុងខណៈនោះ ភពរបស់ស្តេចសក្កទេវរាជ បញ្ចេញអាការក្តៅធ្លូលឡើង ។ សក្កទេវរាជប្រមើលមើលទៅ ជ្រាបនូវស្ថានការណ៍នោះ ហៅវិស្សុកម្មទេវបុត្រមកប្រាប់ថា ៖

> "នែវិស្សុកម្មទេវបុត្រ ជនមានគុណធ្ងន់ពីរនាក់នោះ កំពុងចេញចាកស្រុកចូលទៅកាន់ព្រៃហិមពាន្ត ។ ការដែលពួកគេបាននូវជម្រកនៅអាស្រ័យទើបគួរ, លោកចូរទៅនិម្មិតបណ្ណសាលានិងគ្រឿងបរិក្ខារសម្រាប់អ្នកបួសជូនតាបសទាំងពីរ ក្នុងទីប្រមាណកន្លះយោជន៍ជុំវិញក្បែរស្ទឹង**មិគសម្មតា** រួចហើយ សឹមត្រឡប់មកវិញ" ។

វិស្សុកម្មទេវបុត្រនោះ ទទួលព្រះរាជបញ្ជា មកចាត់ចែងសព្វគ្រប់តាមន័យដូចបានចែងក្នុងតេមិយជាតក គឺបានបណ្តេញហ្វូងម្រឹគកាច ៗ និងពួកបក្សីដែលមានសំឡេងមិនជាទីគាប់ចិត្ត និងនិម្មិតផ្លូវថ្មើរជើង

រួចរាល់ហើយ បានវិលត្រឡប់ទៅកាន់លំនៅឋានខ្លួនវិញ ។ ចំណែកឯបុរសទុកូល និងនាងបារិកាទាំងពីររូប មើលឃើញផ្លូវនោះ ក៏បានដើរតាមរៀងរាបដរាបដល់អាស្រមបទមួយ ។ ទុកូលតាបសចូលទៅក្នុងបណ្ណសាលា មើលឃើញនូវគ្រឿងបរិក្ខាររបស់បព្វជិត ដឹងថារបស់អស់ទាំងនេះគឺ សក្កទេវរាជប្រទានដល់ខ្លួន គាត់ក៏ផ្លាស់សម្លៀកបំពាក់គ្រហស្ថចេញ ប្តូរមកស្លៀកសំពត់សំបកធ្មៃពណ៌ក្រហមមួយផ្ទាំងដណ្តប់មួយផ្ទាំង ពាក់ស្បែកខ្លាឥតក្រចកឆៀងស្មាម្ខាង ចងក្តួចសក់ជាជដាមណ្ឌល[១៤]កាន់ភេទជាឥសី រួចហើយបានប្រាប់ឲ្យនាងបារិកាស្លៀកពាក់ជាភេទអ្នកបួសដែរ ។ ក្រោយពេលបួសរួច ជនទាំងពីរនាក់រស់នៅក្នុងទីនោះចម្រើនមេត្តាភាវនា ផ្សាយទៅក្នុងកាមាវចរភូមិ[១៥] ។ ដោយអានុភាពនៃមេត្តាចិត្តរបស់តាបសទាំងពីរ ហ្វូងម្រឹគនិងបក្សីទាំងអស់តែងមានមេត្តាចិត្តចំពោះគ្នាទៅវិញទៅមក ឥតមានសត្វណាបៀតបៀនសត្វណាឡើយ ។ តាំងពីពេលនោះ តាបសិនីបារិកាតែងដងទឹកឆាន់ ទឹកប្រើប្រាស់មកតម្កល់ទុក បោសអាស្រមបទ និងធ្វើកិច្ចការងារទាំងឡាយទាំងពួង ។ វេលាទៅរកអាហារ ជនទាំងពីរនាក់ តែងដើរបណ្តើរគ្នាទៅបេះផ្លែឈើតូចធំ យកមកបរិភោគ រួចចូលទៅកាន់បណ្ណ-

[១៤] ផ្នួងសក់រាងមូលរបស់តាបស ។

[១៥] អបាយភូមិ ៤ (នរក, ប្រេត, តិរច្ឆាន, អសុរកាយ) មនុស្ស ១ ទេវលោក ៦ ជាន់ ។

សាលារៀង ៗ ខ្លួន ធ្វើសមណធម៌ នេះគឺជារបៀបរស់នៅរបស់តាបស ទាំងពីរក្នុងទីនោះ ។

## ព្រះមហាសត្វចាប់បដិសន្ធិ

សក្កទេវរាជ តែងមកកាន់ទីឧបដ្ឋានរបស់តាបសទាំងពីរនោះ, ក្នុងថ្ងៃមួយ លោកបានប្រមើលមើលតាមលំដាប់ ក៏ឃើញនូវអន្តរាយថា "តាបសទាំងពីររូបនេះ នឹងខ្វាក់ភ្នែកសងខាងទាំងពីរនាក់" រួចចូលទៅរកតាបសទុកូលតាបស ដល់ហើយថ្វាយបង្គំរួចអង្គុយក្នុងទីសមគួរពោលយ៉ាងនេះថា ៖

"បពិត្រលោកម្ចាស់, អន្តរាយនឹងមានប្រាកដដល់លោកម្ចាស់, ការដែលលោកមានកូនម្នាក់ គ្រាន់នឹងជួយទំនុកបម្រុងបម្រើ ទើបជាការប្រសើរ, ចូរលោកសេពលោកធម៌[១៦]ចុះ" ។

លំដាប់នោះ ទុកូលតាបសតបនឹងសក្កទេវរាជវិញថា ៖

"បពិត្រស្តេចសក្កៈ, ថ្វីក៏ព្រះអង្គមានព្រះបន្ទូលដូច្នេះ, កាលអាត្មាទាំងពីរនាក់ នៅជាគ្រហស្ថគ្រប់គ្រងផ្ទះនៅឡើយ ខ្ពើមលោកធម៌ ដូចខ្ពើមគំនរលាមក ដែលមានហ្វូងដង្កូវវាររវាមអ៊ីចឹង, ចំណង់បើ

---

[១៦] ធម៌សម្រាប់លោក គឺអាការ, សណ្តាប់ធ្នាប់ ឬធម្មតានៃជីវិតរស់នៅក្នុងលក្ខណៈជាប្តីប្រពន្ធ ដែលត្រូវប្រព្រឹត្តជាមួយគ្នាជាធម្មតា ។

ឥឡូវនេះ អាត្មាទាំងពីរនាក់ចូលមកក្នុងព្រៃបួសជាឥសីហើយ តើនឹងឲ្យប្រព្រឹត្តនូវលោកធម៌មានសភាពបែបនោះ ដូចម្ដេចកើតទៅ?”

គ្រានោះ សក្កទេវរាជមានបន្ទូលនឹងទុកូលតាបសថា ៖

“បពិត្រលោកម្ចាស់, ប្រសិនបើលោកមិនអាចធ្វើយ៉ាងនេះកើតទេ, សូមលោក គ្រាន់តែយកដៃបបោសអង្អែលផ្ចិតរបស់តាបសិនីបារិកា ក្នុងពេលមានរដូវចុះ” ។

“ត្រឹមប៉ុណ្ណេះ អាត្មាអាចធ្វើបាន” ទុកូលតាបសយល់ព្រម ។

សក្កទេវរាជ ថ្វាយបង្គំលាទុកូលតាបស វិលទៅកាន់លំនៅឋានរបស់ព្រះអង្គនៅឯត្រៃត្រិង្សវិញ ។

ទុកូលតាបសប្រាប់ហេតុការណ៍នោះដល់តាបសិនីបារិកា រួចបានយកដៃបបោសអង្អែលផ្ចិតរបស់តាបសិនី ក្នុងពេលនាងមានរដូវ ។ គ្រានោះ ព្រះពោធិសត្វច្យុតចាកទេវលោកមកចាប់បដិសន្ធិក្នុងផ្ទៃរបស់តាបសិនីបារិកា ។ ១០ ខែក្រោយមក តាបសិនីបានសម្រាលកូនប្រុសមួយដែលមានពណ៌សម្បុរល្អដូចមាស ហេតុនោះ ទើបម្ដាយឪពុកដាក់ឈ្មោះឲ្យថា “**សុវណ្ណសាម**” ។

ក្នុងពេលតាបសិនីបារិកាចូលទៅក្នុងព្រៃដើម្បីរកបេះផលាផល,

កិន្នរី[១៧] ទាំងឡាយដែលនៅក្នុងព្រៃភ្នំ តែងមកធ្វើកិច្ចជាមេដោះរបស់ព្រះពោធិសត្វ ។ ម្ដាយឪពុកទាំងពីរនាក់ តែងផ្ងូតទឹកព្រះពោធិសត្វរួចយកទៅដាក់ឲ្យដេកក្នុងបណ្ណសាលាម្នាក់ឯង ហើយអ្នកទាំងពីរទៅក្នុងព្រៃរកបេះផ្លែឈើតូចធំ ។ ក្នុងខណៈនោះ កិន្នរទាំងឡាយបីកុមារសុវណ្ណសាមយកទៅផ្ងូតទឹកនៅឯជ្រោះភ្នំគិរិកន្ទរា ជាដើម រួចបីឡើងទៅលើកំពូលភ្នំ តុបតែងខ្លួនប្រាណកុមារដោយផ្កាផ្សេង ៗ ហើយយកហរិតាលមនោសិលា[១៨]ជាដើម មកបុកលើផ្ទាំងសិលាយកផង់មកផ្តិតជាចំណុចត្រង់ថ្ងាសរបស់សុវណ្ណសាមកុមារ ហើយក៏នាំចុះទៅដាក់ផ្ដេកនៅក្នុងបណ្ណសាលាវិញ ។ ចំណែកតាបសិនីបារិកា លុះត្រឡប់មកពីបេះផលាផលវិញ តែងតែបំបៅដោះកូន ។ ចំណេរកាលតមកសុវណ្ណសាម កុមារក៏បានចម្រើនវ័យវឌ្ឍនាការដល់អាយុ ១៦ ឆ្នាំ ម្ដាយនិងឪពុក តែងតែបីបាច់រក្សាដោយព្រហ្មវិហារធម៌ និងតែងប្រាប់ឲ្យអង្គុយក្នុងបណ្ណសាលា ហើយខ្លួនឯងចូលទៅក្នុងព្រៃរកមើមឈើនិងផ្លែឈើតូចធំ ។ ចំណែកឯសុវណ្ណសាមពោធិសត្វគិតក្នុងចិត្តថា ៖

---

[១៧] (ន(. ឈ្មោះបក្សីញីមួយប្រភេទ ថាមានរូបដូចមនុស្ស មានស្លាបហើរបាន មាននិយាយតែក្នុងរឿងបុរាណ ។ បុំកិន្នរ . ។

[១៨] (ន.) (សំ.),(បា.) (**ហរិតាល** “វត្ថុមួយប្រភេទស្មើរជាថ្មតែសាច់ទន់សម្បុរលឿងខ្ចីដុសឬកិនយកផង់ប្រើការធ្វើពណ៌លឿងជាដើម”) ។ **ហរិតាលមនោសិលា** មនោ-សិលាសម្បុរលឿងខ្ចី ។

"នៅថ្ងៃណាមួយ ម្តាយឪពុកអញនឹងជួបគ្រោះថ្នាក់អ្វីមួយពុំខាន" គិតដូច្នេះហើយ ក៏កំណត់ចំណាំផ្លូវដែលម្តាយឪពុកធ្វើដំណើរទៅនោះ ។

## ម្តាយឪពុកពោធិសត្វពិការភ្នែក

តមកក្នុងថ្ងៃមួយ កាលដែលតាបសទាំងពីររកមើមឈើនិងផ្លែឈើតូចធំបានហើយ លុះព្រះសុរិយារសៀលទន់ទាប តាបសទាំងពីរធ្វើដំណើរត្រឡប់មកវិញ ជិតដល់អាស្រមបទ ស្រាប់តែមានពពកចុះអព្ភខ្មៅងងឹត ហើយបង្អុរភ្លៀងចុះយ៉ាងខ្លាំង ។ អ្នកទាំងពីរឡើងទៅលើដំបូក ឈរជ្រកនៅក្រោមដើមឈើធំមួយដើម ។ នៅខាងក្នុងដំបូកនោះមានសត្វអាសិរពិសមួយអាស្រ័យនៅ ។ ទឹកភ្លៀងដែលស្រក់លើរូបកាយរបស់តាបសទាំងពីរ បានហូរជ្រាបចូលទៅក្នុងរូងពស់ដោយទាំងក្លិនញើសទៅជាមួយផង ក៏ទៅប៉ះនឹងខ្នងច្រមុះអាសិរពិស បណ្តាលឲ្យអាសិរពិសនោះខឹងឆេវ ហើយក៏បញ្ចេញចំហាយពិសតាមរន្ធច្រមុះ បណ្តាលឲ្យតាបសទាំងពីរងងឹតភ្នែកមើលគ្នាមិនឃើញ ។ ទុកូលតាបសហៅតាបសិនីបារិកាថា ៖

"នែបារិកា ភ្នែកខ្ញុំងងឹតទាំងសងខាងហើយ, ខ្ញុំមើលនាងមិនឃើញទេ" ។

"អ្នកអើយ, ខ្ញុំក៏អ៊ីចឹងដែរ" បារិកាឆ្លើយតប ។

តាបសទាំងពីរ កាលមើលផ្លូវពុំឃើញ ឈរនៅទីនោះយំខ្សឹកខ្សួលថា ៖

"យើងលែងបានរស់តទៅទៀតហើយឥឡូវនេះ" ។

**កំណត់សម្គាល់**

*សំណួរ ៖*

តើបុព្វកម្មដូចម្ដេច ដែលបណ្ដាលឲ្យតាបសទាំងពីររូបខ្វាក់ភ្នែក ?

**ចម្លើយ ៖**

បានឮមកថា កាលពីអតីតជាតិ តាបសទាំងពីរនោះកើតក្នុងត្រកូលពេទ្យ ។ ពេទ្យជាប្ដីបានព្យាបាលរោគភ្នែករបស់បុរសម្នាក់ ដែលជាមហាធន[១៩] ។ បុរសមហាធនមិនបានឲ្យទ្រព្យអ្វីបន្តិចបន្តួចដល់ពេទ្យនោះសោះ ។ លំដាប់នោះ ពេទ្យខឹង ហើយត្រឡប់ទៅផ្ទះខ្លួនវិញប្រាប់ប្រពន្ធថា ៖

---

[១៩] អ្នកមានទ្រព្យច្រើនស្ដុកស្ដម្ភ ។

*"នៃភាន[២០], បងបានព្យាបាលរោគភ្នែកឲ្យបុរសម្នាក់, ឥឡូវនេះគេមិនឲ្យថ្លៃឈ្នួលដល់បងទេ, តើយើងនឹងធ្វើដូចម្ដេច ?"*

*ប្រពន្ធពេទ្យស្ដាប់ហើយ ខឹងឆេវឆាវ ឲ្យយោបល់ដល់ប្ដីថា ៖*

*"យើងចាំបាច់ត្រូវការថ្លៃឈ្នួលពីគេធ្វើអ្វី បងផ្សំតែថ្នាំមួយមុខដាក់ឲ្យគេខ្វាក់ភ្នែកទាំងសងខាងទៅ វាជាការស្រេច" ។*

*ពេទ្យជាប្ដីយល់ព្រម ក៏ដើរទៅកាន់សម្នាក់របស់បុរសមហាធន បានផ្សំថ្នាំដាក់តាមយោបល់របស់ប្រពន្ធ ។ បុរសមហាធននោះ មិនយូរប៉ុន្មានក៏ខ្វាក់ភ្នែកទាំងសងខាង ។ ដោយសារបុព្វកម្មនេះ ទើបតាបសទាំងពីរនោះត្រូវខ្វាក់ភ្នែកសងខាងទាំងពីរនាក់ ក្នុងបច្ចុប្បន្នជាតិនេះ ។*

## សុវណ្ណសាមបម្រើម្ដាយឪពុក

*និយាយពីសុវណ្ណសាមព្រះមហាសត្តនៃយើងវិញ ជញ្ជឹងគិតនៅឯខ្លួនម្នាក់ឯងថា ៖*

*"ម្ដាយឪពុករបស់អញ សព្វដង តែងតែមកក្នុងវេលានេះ, ឥឡូវ*

---

*[២០] (បុ. ស.) (ព. បុ.) គេហ៍; ពាក្យសម្រាប់ប្ដីហៅប្រពន្ធ ក្នុងទីចំពោះមុខដោយស្មោះស្មើ ជាសម្ដីរាបសារបស់ប្រជាពលរដ្ឋក្នុងបុរាណសម័យ : ម្នាលភាន, ភានអើយបាយឆ្អិនហើយឬនៅ ?; សម្រាប់ប្រពន្ធហៅប្ដីក៏បាន ។*

នេះ អញមិនដឹងពួកគាត់មានរឿងអ្វីកើតឡើងទេ, អញនឹងទៅមើលផ្លូវដែលលោកទាំងពីរតែងធ្វើដំណើរសព្វដងមើល៍" ។

សុវណ្ណសាមដើរទៅតាមផ្លូវ ដង្ហោយហៅខ្លាំង ៗ ថា "ម៉ែ! ពុក! ៗ" ។ ម្ដាយឪពុក ចាំសំឡេងរបស់កូនបាន ក៏ស្រែកតបទៅវិញដោយសេចក្ដីស្រឡាញ់កូនថា ៖

"ហៃសុវណ្ណសាមកូន, កន្លែងនេះមានគ្រោះថ្នាក់,
កុំចូលមកទីនេះអី ណ៎ាកូន" ។

គ្រានោះ សុវណ្ណសាមរកកំណាត់ឈើវែងមួយដើម ហុចទៅឲ្យម្ដាយឪពុក ហើយប្រាប់ពួកគាត់ថា ៖

"បើអ៊ីចឹង សូមលោកកាន់ចុងឈើនេះ ហើយដើរមករកខ្ញុំ" ។ ម្ដាយឪពុកក៏ចាប់ចុងឈើ ដើរសន្សឹម ៗ មករកសុវណ្ណសាម ។ គ្រានោះ សុវណ្ណសាមកុមារសួរម្ដាយឪពុកថា ៖

"ព្រោះហេតុអ្វី បានជាលោកទាំងពីរខ្វាក់ភ្នែកអស់យ៉ាងនេះ?"

គ្រានោះ ម្ដាយឪពុកប្រាប់កូនថា ៖

"ហៃកូនអើយ, នាកាលមេឃកំពុងភ្លៀង យើងនាំគ្នាមកឈរជ្រក

ទៀបគល់ឈើលើដំបូកនេះ, ដោយហេតុប៉ុណ្ណោះឯងណាកូន
អើយ" ។

សុវណ្ណសាម គ្រាន់តែស្ដាប់សម្ដីរបស់ម្ដាយឪពុកភ្នាម យល់ច្បាស់ថា "ក្នុងទីនោះ ជាក់ជាមានអាសិរ្ពិស, វាខឹង ទើបបញ្ចេញផ្សែងតាមច្រមុះ ឲ្យជះចំហាយពិសឡើង" សុវណ្ណសាម សម្លឹងមើលទៅម្ដាយឪពុក ស្រាប់តែយំផង សើចផង ។

ម្ដាយឪពុកសួរថា ៖

"ហៃកូន, ហេតុអ្វីបានជាអ្នកយំផង សើចផង ?"

សុវណ្ណសាម ឆ្លើយថា ៖

"បពិត្រអ្នកម្ដាយលោកឪពុក, ខ្ញុំយំព្រោះសោកស្ដាយភ្នែកទាំងគូរបស់លោកដែលវិនាស ក្នុងពេលដែលខ្ញុំនៅវ័យក្មេងយ៉ាងនេះ ។ ខ្ញុំសើច ព្រោះនឹកឃើញថា ខ្ញុំនឹងបានទំនុកបម្រុងលោកទាំងពីរ ចាប់តាំងពីថ្ងៃនេះតរៀងទៅ ។ បពិត្រអ្នកម្ដាយលោកឪពុក, លោកទាំងពីរ កុំព្រួយបារម្ភអ្វីឡើយ, ខ្ញុំនឹងផ្គត់ផ្គង់លោកទាំងពីរ ឲ្យអស់ពីចិត្ត" ។

សុវណ្ណសាម លួងលោមម្ដាយឪពុក នាំគាត់ទាំងពីរត្រឡប់ទៅអាស្រម-

បទ[21] ។ សុវណ្ណសាមក៏ចាប់ផ្ដើមចងខ្សែធ្វើជាស្ពួគ្រប់ទីកន្លែង គឺកន្លែងសម្រាកវេលាយប់ ១ កន្លែងសម្រាកវេលាថ្ងៃ ១ កន្លែងចង្ក្រម ១ បណ្ណ-សាលា ១ វច្ចដ្ឋាន[22] ១ បស្សាវដ្ឋាន[23] ១ សម្រាប់ឲ្យម្ដាយឪពុក ដើរស្ទួទៅមកបានស្រួល ។ តាំងពីពេលនោះមក សុវណ្ណសាម តែងទុកម្ដាយឪពុក ឲ្យនៅក្នុងអាស្រមបទ ហើយខ្លួនឯងទៅរកជីកមើមឈើ បេះផ្លែឈើ ជាដើម មកទុកក្នុងបណ្ណសាលា សម្រាប់ឲ្យម្ដាយឪពុកបរិភោគតាមសេចក្ដីត្រូវការ ។ ជារៀងរាល់ព្រឹក សុវណ្ណសាមកុមារ តែងភ្ញាក់ពីព្រលឹម បោសសម្អាតកន្លែងរបស់ម្ដាយឪពុក រួចថ្វាយបង្គំពួកគាត់ កណ្ដៀតក្អម ដើរចេញទៅកាន់ស្ទឹង**មិគសម្មតា** ដងទឹកសម្រាប់ផឹក និងទឹកសម្រាប់ប្រើប្រាស់ យកមកតម្កល់ទុក រួចជូនឈើស្ទន់[24] ទឹកលុបមុខ ជាដើមដល់ម្ដាយឪពុក បន្ទាប់មកជូនផ្លែឈើផ្អែម ៗ ឲ្យគាត់ពិសា ។ កាលបើម្ដាយឪពុកបរិភោគ និងខ្ពុរមាត់រួច ទើបសុវណ្ណសាមបរិភោគ ដោយខ្លួនឯងជាខាងក្រោយ ។ រាល់ពេលដែលព្រះមហាសត្ត

---

[21] អាស្រមបទ (--ស្រំ-ម៉ៈបត់; សំ. អាគ្រមបទ; បា. អស្សមបទ) ទីអាស្រម, ទីក្បែរឬជុំវិញអាស្រម : តាបសតែងបោសសម្អាតអាស្រមបទតាមពេលកំណត់ពុំដែលខាន ។

[22] កន្លែងសម្រាប់បន្ទោបង់លាមក ។

[23] កន្លែងសម្រាប់បន្ទោបង់នោម, កន្លែងនោម ។

[24] (ន.) ប្រដាប់សម្រាប់ដុសជម្រះធ្មេញ : ទំពាស្ទន់ស្រស់, ដំស្ទន់ (ខ្មែរច្រើនប្រើវល្លិស្រស់ឬមែកឈើស្រស់ដែលមានរសប្រហាតឬស្មែងដូងស្មែងស្វាស្រស់ក៏ប្រើ) ។

ចូលទៅក្នុងព្រៃរកបេះផ្លែផលាផល លោកតែងថ្វាយបង្គំលាម្ដាយឪពុក។ កាលសុវណ្ណសាមធ្វើដំណើរទៅនោះ តែងមានហ្វូងម្រឹគចោមរោមដើរទៅជាមួយ ។ សុវណ្ណសាមដើរបេះផលាផលនៅតាមជើងភ្នំ មានពួកកិន្នរមកចោមរោមជាបរិវារ ។ លុះដល់វេលាល្ងាច សុវណ្ណសាមត្រឡប់មកអាស្រមបទវិញ កណ្ដៀតក្អមទៅដងទឹក យកមកផ្ងូតនិងលាងជើងតាមសេចក្ដីត្រូវការរបស់ម្ដាយឪពុកនិងរៀបចំអំបែងភ្លើងផ្ដងដៃជើងជូនលោកទាំងពីរ ។ កាលដែលលោកទាំងពីរកំពុងអង្គុយក្បែរអំបែងភ្លើង សាមកុមារតែងជូនផលាផលដល់លោកទាំងពីរបរិភោគ ។ ពេលលោកទាំងពីរបរិភោគរួច ទើបសុវណ្ណសាមបរិភោគដោយខ្លួនឯងជាខាងក្រោយ បន្ទាប់មក បានរៀបចំទុកដាក់របស់របរ មើមឈើ ផ្លែឈើដែលនៅសេសសល់ឲ្យមានរបៀបរៀបរយ ។ សុវណ្ណសាមកុមារ តែងបម្រើម្ដាយឪពុកបែបនេះ ជារៀងរាល់ថ្ងៃ ។

# ជំពូកទី៣

## ស្ដេចបីឡិយក្សជួបសុវណ្ណសាម

### ស្ដេចបីឡិយក្សបាញ់សុវណ្ណសាម

*ក្នុងសម័យនោះ មានព្រះរាជាមួយអង្គព្រះនាមថា **បីឡិយក្ស**[២៥] ទ្រង់សោយរាជ្យក្នុងនគរពារាណសី ។ ស្ដេចបីឡិយក្សនោះ ហេតុតែញៀនញ៉ាមសោយសាច់ម្រឹគ បានដាក់រាជ្យថ្វាយព្រះមាតាស្នងជំនួស ព្រះអង្គឯងរៀបចំសៀតអាវុធទាំង ៥ យាងចូលទៅព្រៃហិមពាន្ត រកបាញ់ម្រឹគយកសាច់សោយ ។ ព្រះអង្គយាង ៗ ទៅ ក៏បានទៅដល់ស្ទឹងមិគសម្មតា យាងទៅមុខទៀតក៏បានទៅដល់កំពង់ដែលសុវណ្ណសាមតែងតែមកដងទឹក ទ្រង់បានប្រទះឃើញស្នាមជើងម្រឹគ ក៏កាច់មែកឈើមានពណ៌ដូចកែវមណីធ្វើជាស៊ុមទ្រុមសំងំពួនក្នុងទីនោះ ហើយដាក់កូនសរដែលលាបដោយថ្នាំពិស យឹតធ្នូត្រៀមចាំបាញ់ម្រឹគ ។*

*គាប់ចួនគ្រានោះ ជាវេលារសៀល ចំពេលដែលព្រះមហាសត្តវិលមកពីបេះផលាផល យកទុកក្នុងអាស្រមបទហើយ ថ្វាយបង្គំម្ដាយឪពុកដោយប្រាប់លោកទាំងពីរថា នឹងទៅដងទឹកផឹក រួចកណ្ដៀតក្អមដើរចេញទៅ ដោយមានហ្វូងម្រឹគចោមរោមទៅជាមួយដូចសព្វដង ។*

---

*[២៥] ព្រះរាជាអង្គនេះ ជាមនុស្សតែមានចំណូលចិត្តសោយសាច់ ។*

នៅតាមផ្លូវ ព្រះមហាសត្តបានដាក់ក្អមលើខ្នងសត្វម្រឹគពីរដែលវាដើរទន្ទឹមគ្នា លោកដើរបណ្ដើរយកដៃទប់ក្អមបណ្ដើរក្រែងលោធ្លាក់ រហូតទៅដល់កំពង់ទឹកស្ទឹងដែលតែងដងទឹកដូចសព្វមួយដង ។ ស្ដេចបីឡិយក្ស ឈរពួននៅក្នុងមែកឈើស៊ីមទ្រុម រំពៃព្រះនេត្រសម្លឹងមើលទៅស្រាប់តែឃើញព្រះមហាសត្តកំពុងយាងមកដោយអាការដូច្នោះ ទ្រង់គិតក្នុងព្រះរាជហឫទ័យថា ៖

"អញដើរពនេចរ អស់រយៈពេលមានប្រមាណប៉ុណ្ណោះ មិនដែលឃើញមនុស្សណាម្នាក់សោះ, តើអ្នកនោះ ជាទេវតាឬជានាគហ្ន៎ ? ប្រសិនបើអញចូលទៅជិតសួរ, បើគេជាទេវតា គេនឹងហោះទៅឰដ៏អាកាស, បើគេជានាគ គេនឹងជ្រែកចូលទៅក្នុងផែនដី, ម្យ៉ាងវិញទៀត អញមិនមែនដើរពនេចរក្នុងព្រៃហិមពាន្ត ជារៀងរហូតឯណា អញនឹងត្រឡប់ទៅកាន់នគរពារាណសីវិញ, ប្រាកដជាមានមនុស្សម្នាក្នុងនគរសួរអញថា ពេលព្រះអង្គនៅក្នុងព្រៃហិមពាន្ត តើបានឃើញភាពអស្ចារ្យអ្វីខ្លះ ? កាលបើគេសួរដូច្នេះ អញនឹងប្រាប់ថា យើងបានឃើញសត្វបែបនេះ, កាលបើគេសួរអញថា តើសត្វនោះជាអ្វី, បើអញប្រាប់ថាមិនដឹង ប្រាកដជាពួកគេតិះដៀលអញមិនខាន, ព្រោះហេតុនោះ អញត្រូវបាញ់អ្នកនោះធ្វើឲ្យមានកម្លាំងខ្សោយសិន សឹមសួរគេតាមក្រោយ" ។

គ្រានោះ ហ្វូងម្រឹគទាំងនោះចុះទៅផឹកទឹកជាមុនរួចហើយទើបឡើង មកវិញ ។ រីឯព្រះពោធិសត្វ ដើរចុះសន្សឹម ៗ ដូចព្រះមហាថេរអ្នករៀន វត្តប្រតិបត្តិ លុះរំងាប់សេចក្តីក្រវល់ក្រវាយរួច សាមកុមារដើរឡើងមក វិញ ស្លៀកសំពត់សំបកឈើពណ៌ក្រហមមួយផ្ទាំងនិងដណ្តប់មួយផ្ទាំង ពាក់ធៀងស្មាដោយស្បែកម្រឹគ លើកក្អមជួតទឹកឲ្យស្អាតរួច ដាក់លើ ចង្កេះស្មាខាងឆ្វេង ។ ពេលនោះឯង ព្រះរាជាត្រិះរិះថា "ដល់ពេល ដែលត្រូវបាញ់ហើយ" ស្តេចក៏ទ្រង់លើកធ្នូដាក់គ្រាប់សរពិសយឹតបាញ់ តម្រង់ ឆ្ពោះទៅព្រះមហាសត្តពីផ្នែកខាងស្តាំ ធ្លុះធ្លាយទៅផ្នែកខាង ឆ្វេង ។ ហ្វូងម្រឹគឮស្នូរព្រួញត្រូវពោធិសត្វលាន់សំឡេងដ៏គួររន្ធត់ ដូច្នោះ ភ័យខ្លាចស្លាប់ ក៏បោលរត់រកអាយុរៀង ៗ តែខ្លួន ។ ចំណែក សុវណ្ណសាម ថ្វីបើត្រូវគ្រាប់ព្រួញមុតធ្លុះទទឹងខ្លួនយ៉ាងពេញទំហឹង យ៉ាងនោះហើយក៏ដោយ ក៏ដំហររបស់លោកនៅតែឈរលើក្អមយ៉ាង នោះដដែល លោកខំតាំងស្មារតីដាក់ក្អមទឹកចុះសន្សឹម ៗ នៅលើគំនរ ដីខ្សាច់ កំណត់ចំណាំនូវទិសហើយ ក៏ប្រះខ្លួនដេកបែរក្បាលទៅត្រង់ ទិសអាស្រមបទរបស់ម្តាយឪពុក ប្រៀបដូចជារូបបដិមាមាសនៅលើដី ខ្សាច់ពណ៌ទឹកប្រាក់ដ៏ចែងចាំងផ្ទេក ៗ ។ សុវណ្ណសាមតាំងស្មារតី រឹងប៉ឹងប្រឹងនិយាយទាំងក្អួតឈាមបណ្តើរថា ៖

"ក្នុងព្រៃហិមពាន្តនេះ រកបុគ្គលអ្នកមានពៀរជាមួយនឹងខ្ញុំ មិន មានទេ, ទាំងអ្នកមានពៀរជាមួយនឹងម្តាយឪពុកខ្ញុំ ក៏មិនមានដែរ"។

សុវណ្ណសាមនិយាយបណ្តើរចេញឈាមតាមមាត់បណ្តើរ តែមើលមិនឃើញព្រះរាជាសោះ ។

**ទំនួញសុវណ្ណសាម**

សុវណ្ណសាមសួរថា ៖

"កោ នុ មំ ឧសុនា វិជ្ឈិ បមត្តំ ឧទហារកំ
ខត្តិយោ ព្រាហ្មណោ វេស្សោ កោ មំ វិទ្ធា និលីយសិ"។

"នរណាបាញ់ខ្ញុំកំពុងលីក្អមទឹកភ្លេចស្មារតី ដោយព្រួញ ? តើអ្នកជានរណា ? ជាក្សត្រ ឬជាព្រាហ្មណ៍ ឬជាវេស្សៈ ម្តេចក៏បាញ់ខ្ញុំហើយលាក់ខ្លួនពួនអាត្មាអ៊ីចឹង ?"

សុវណ្ណសាមពោលថា លោកភ្លេចស្មារតី គឺលោកមិនបានតាំងស្មារតីក្នុងការចម្រើនមេត្តា (មេត្តាភាវនា) ។ តាមពិត ពាក្យនេះសំដៅយកការភ្លេចតែមួយខណៈប៉ុណ្ណោះ ។

លុះពោលយ៉ាងនេះហើយ ដើម្បីបង្ហាញសាច់ក្នុងរាងកាយរបស់លោកថាជារបស់មិនគួរបរិភោគ ចំពោះអ្នកបាញ់ សុវណ្ណសាមបានពោលបន្តថា ៖

"ន មេ មំសានិ ខជ្ជានិ ចម្មេនត្ថោ ន វិជ្ជតិ
អថ កេន នុ វណ្ណេន វិទ្ធេយ្យំ មំ អមញ្ញថ"។

"សាច់របស់ខ្ញុំ មិនមែនជារបស់គួរបរិភោគទេ ទាំងស្បែកខ្ញុំក៏មិនមែនគួរដល់តម្រូវការណាដែរ កាលបើដូច្នេះ ម្តេចឡើយក៏អ្នកសម្គាល់ខ្ញុំថាគួរបាញ់ទៅវិញ ?"

លុះពោលដូច្នេះរួច សុវណ្ណសាមសួរទៅអ្នកបាញ់ទាក់ទងដោយឈ្មោះជាដើមថា ៖

"កោ វា ត្វំ កស្ស វា បុត្តោ កថំ ជានេមុ តំ មយំ
បុដ្ឋោ មេ សម្ម អក្ខាហិ កិំ មំ វិទ្ធា និលីយសិ"។

"តើអ្នកជានរណា ? ជាកូនរបស់អ្នកណា ? ធ្វើម៉េចខ្ញុំស្គាល់អ្នកបាន? ម្នាលសម្លាញ់ ខ្ញុំសួរអ្នកហើយ ចូរអ្នកប្រាប់មូលហេតុដែលអ្នកពួនបាញ់ខ្ញុំហើយពួនមកមើល" ។

លុះពោលយ៉ាងនេះហើយ សុវណ្ណសាមនៅស្ងៀម ។ ចំណែកព្រះរាជាទ្រង់ព្រះសណ្តាប់ដូច្នោះ មានព្រះចិន្តាថា ៖

"អ្នកនេះ ទោះបីត្រូវយើងបាញ់កូនសរពិសត្រូវមួយគ្រាប់ដួលម៉ឹងហើយ នៅតែមិនជេរប្រទេចផ្តាសាមករកយើង បែរជាសួររក

យើងដោយពាក្យជាទីស្រឡាញ់ទៅវិញ ហាក់បីដូចជាយកទឹកស្រោចដួងហឫទ័យរបស់យើងឲ្យត្រជាក់, អញនឹងចេញទៅមើលគេ" ។

ព្រះអង្គមានព្រះរាជតម្រិះដូច្នេះ ស្ដេចទ្រង់យាងទៅឈរជិតព្រះមហាសត្វ ហើយមានបន្ទូលថា ៖

"រាជាហមស្មិ កាសីនំ　　បីឡិយក្ខោតិ មំ វិទូ
លោភា រដ្ឋំ បហិត្វាន　　មិគមេសំ ចរាមហំ ។

ឥស្សត្ថេ ចស្មិ កុសលោ　　ទឡ្ហធម្មោតិ វិស្សុតោ
នាគោបិ មេ ន មុច្ចេយ្យ　　អាគតោ ឧសុបាតនំ" ។

"យើងជាព្រះរាជារបស់ពួកអ្នកដែនកាសី យើងឈ្មោះ បីឡិយក្ស យើងបានលះបង់ដែនមកត្រាច់ស្វែងរកម្រឹគ ព្រោះលោភសោយសាច់ម្រឹគ មួយវិញទៀត យើងជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថាជាខ្មាន់ធ្នូដ៏ស្ទាត់ជំនាញ ទ្រទ្រង់នូវធ្នូដ៏មាំ ទោះបីដំរីក៏ដោយ ឲ្យតែមកចំមុខព្រួញរបស់យើង មិនអាចរួចខ្លួនបានឡើយ" ។

ហេតុដែលស្ដេចបីឡិយក្សប្រាប់ថា ព្រះអង្គជាព្រះរាជា ព្រោះព្រះអង្គមានព្រះបរិវិតក្កៈថា ទោះទេវតាក្ដី នាគក្ដី គង់ចេះនិយាយ

ភាសាមនុស្សដោយពិត អញមិនស្គាល់គេជាទេវតាឬជានាគ ឬក៏ជាមនុស្សទេ ប្រសិនបើគេក្រោធ គេអាចញុាំងអញឲ្យវិនាសបាន ប៉ុន្តែបើអញប្រាប់ថា ខ្លួនអញជាព្រះរាជា, ធម្មតា គ្មានទេអ្នកដែលមិនខ្លាចអំណាចស្តេចផែនដី ។ ព្រោះហេតុនោះ ទើបព្រះបាទបីឡិយក្សហាព្រះឱស្ឋដំបូងប្រាប់ថា យើងជាព្រះរាជា (រាជាហមស្មិ) ដើម្បីឲ្យសុវណ្ណសាមដឹងថាព្រះអង្គគឺជាស្តេចផែនដី ។ ការដែលព្រះអង្គប្រាប់ថា ព្រះអង្គឈ្លាសវៃក្នុងសិល្បធ្នូ និងទ្រទ្រង់នូវធ្នូដ៏មាំ គឺទ្រង់ចង់បង្ហាញកម្លាំងថាទ្រង់ជាអ្នកមានសមត្ថភាពអាចលើកឬដាក់ចុះនូវសហស្សថាមធ្នូ គឺធ្នូដែលមានទម្ងន់ខ្លាំង ។

ព្រះរាជាទ្រង់បានពណ៌នាយសសក្តិអំណាចខ្លួនដូច្នេះរួចហើយ ទ្រង់ក៏សាកសួរនាមនិងគោត្ររបស់ព្រះមហាសត្តដូច្នេះ ៖

"កោ វា ត្វំ កស្ស វា បុត្តោ  កថំ ជានេមុ តំ មយំ
បិតុនោ អត្តនោ ចាបិ  នាមគោត្តំ បវេទយ" ។

"ចុះអ្នកជានរណា ? ជាបុត្ររបស់អ្នកណា ? ធ្វើដូចម្តេចទើបយើងស្គាល់អ្នកបាន ? សូមអ្នកប្រាប់នូវនាមនិងគោត្ររបស់បិតាផងរបស់ខ្លួនផង" ។

ឮដូច្នោះ ព្រះមហាសត្តគិតថា ៖

"ប្រសិនបើអញនិយាយថា ខ្លួនអញជាទេព ជានាគ ជាកិន្នរ ឬជាខត្តិយៈជាដើម ណាមួយ ប្រាកដជាស្តេចអង្គនេះជឿពុំខាន, ប៉ុន្តែការដែលពោលពាក្យសច្ចៈចំពោះព្រះអង្គ ទើបគួរ"

រួចលោកតាំងសតិទាំងខ្លួនក្រើកមិនរួច បានពោលទាំងឈាមក្អួតចេញពីមាត់យ៉ាងនេះថា ៖

"នេសាទបុត្តោ ភទ្ទន្តេ    សាមោ ឥតិ មំ ញាតយោ
អាមន្តយឹសុ ជីវន្តំ    ស្វជ្ជេវាហំ គតោ សយេ ។
វិទ្ធោស្មិ បុថុសល្លេន    សវិសេន យថា មិគោ
សកម្ហិ លោហិតេ រាជ    បស្ស សេមិ បរិប្លុតោ ។
បដិវាមគតំ សល្លំ    បស្ស ធិម្ហាមិ លោហិតំ
អាតុរោ ត្យានុបុច្ឆាមិ    កឹ មំ វិទ្ធា និលីយសិ ។
អជិនម្ហិ ហញ្ញតេ ទីបិ    នាគោ ទន្តេហិ ហញ្ញតេ
អថ កេន នុ វណ្ណេន    វិទ្ធេយ្យំ មំ អមញ្ញថ" ។

"បពិត្រព្រះអង្គដ៏ចម្រើន ទូលបង្គំជាកូនរបស់ឥសីដែលជាបុត្ររបស់នាយនេសាទ ពួកញាតិហៅទូលបង្គំជាខ្ញុំកាលដែលរស់នៅមុននេះថា **សាម** ៗ មានពាក្យថា មកណេះសាម, ទៅចុះ សាមជាដើម ។ ថ្ងៃនេះ ទូលបង្គំជាខ្ញុំដេកដល់មាត់មច្ចុរាជហើយ ។ ទូលបង្គំត្រូវព្រះអង្គបាញ់ ហាក់ដូចម្រឹគ ត្រូវព្រានព្រៃបាញ់

*ដោយព្រួញធំមានពិសដ៏ក្លា ។ បពិត្រព្រះរាជា សូមទ្រង់ទតចុះ ទូលបង្គំជាខ្ញុំដេកត្រាំនៅក្នុងថ្លុកឈាមរបស់ខ្លួន ។ សូមទ្រង់ទត ព្រួញដែលមុតពីខាងស្តាំធ្លាយទៅខាងឆ្វេង ទូលបង្គំជាខ្ញុំខ្ពុរឈាម ទូលបង្គំជាខ្ញុំឈឺចាប់ពេតផ្សាណាស់ ទើបទូលសួរព្រះអង្គរឿយ ៗ ថា ម្តេចក៏ទ្រង់បាញ់ទូលបង្គំហើយពួនក្នុងគុម្ពោតព្រៃអ៊ីចឹង ? ខ្លាដំបងគេសម្លាប់ព្រោះស្បែក ដំរីគេសម្លាប់ព្រោះភ្លុកទាំងគូ កាលបើដូច្នោះ តើព្រះអង្គសម្គាល់នូវទូលបង្គំជាខ្ញុំថា គួរបាញ់ ព្រោះហេតុដូចម្តេច ?"*

*ព្រះរាជា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់សុវណ្ណសាមហើយ ទ្រង់មិន ប្រាប់តាមពិតទេ ទ្រង់មានព្រះរាជឱង្ការកុហកថា ៖*

"មិគោ ឧបដ្ឋិតោ អាសិ   អាគតោ ឧសុចាតនំ
តំ ទិស្វា ឧព្វិជី សាម   តេន កោធោ មមាវិសិ" ។

*"ម្រឹគមកប្រាកដចំមុខព្រួញរបស់យើង ឃើញអ្នកហើយក៏ផ្អើល រត់អស់ ម្នាលសាម ព្រោះហេតុនោះ បានជាយើងមានសេចក្តី ក្រោធ គ្របសង្កត់" ។*

*គ្រានោះ ព្រះមហាសត្តក្រាបទូលតបថា៖*

"មានព្រះរាជឱង្ការថាម៉េច មហាបពិត្រ ? ម្រឹគីម្រឹគានៅក្នុងព្រៃហិមពាន្តដែលឃើញទូលបង្គំជាខ្ញុំហើយផ្អើលរត់ មិនមានទេ"

ហើយសុវណ្ណសាមពោលបញ្ជាក់ដូច្នេះថា ៖

"យតោ សរាមិ អត្តានំ　　យតោ បត្តោស្មិ វិញ្ញុតំ
ន មំ មិគា ឧត្តសន្តិ　　អរញ្ញេ សាបទានិបិ ។
យតោ និធឹ បរិហរឹ　　យតោ បត្តោស្មិ យោព្វនំ
ន មំ មិគា ឧត្តសន្តិ　　អរញ្ញេ សាបទានិបិ ។
ភីរូ កិម្បុរិសា រាជ　　បព្វតេ គន្ធមាទនេ
សម្មោទមានា គច្ឆាម　　បព្វតានិ វនានិ ច ។
ន មំ មិគា ឧត្តសន្តិ　　អរញ្ញេ សាបទានិបិ
អថ កេន នុ វណ្ណេន　　ឧត្រាសន្តិ មិគា មមំ" ។

"តាំងពីទូលបង្គំជាខ្ញុំធំដឹងក្តីមក ម្រឹគទាំងឡាយនៅក្នុងព្រៃ ទោះបីស៊ីស្មៅជាអាហារក្តី ស៊ីសត្វដទៃជាអាហារក្តី កាលឃើញទូលបង្គំជាខ្ញុំហើយ ពុំដែលតក់ស្លុតភ័យខ្លាចទេ ។ តាំងពីទូលបង្គំជាខ្ញុំចេះស្ទៀកដណ្តប់សំពត់សំបកឈើ ចម្រើនវ័យវឌ្ឍនាការមក ម្រឹគទាំងឡាយនៅក្នុងព្រៃ ទោះបីស៊ីស្មៅជាអាហារក្តី ស៊ីសត្វដទៃជាអាហារក្តី កាលឃើញទូលបង្គំជាខ្ញុំហើយ ពុំដែលតក់ស្លុត

*ភ័យខ្លាចទេ ។ បពិត្រព្រះរាជា កុំថាឡើយម្រឹគ សូម្បីកិន្នរទាំងឡាយដែលជាសត្វច្រើនដោយការភ័យខ្លាច ដោយកំណើតពីធម្មជាតិ នៅនាភ្នំគន្ធមាទន៍ កាលឃើញទូលបង្គំជាខ្ញុំហើយ ពុំដែលតក់ស្លុតទេ យើងទាំងឡាយតែងរីករាយជាមួយគ្នា ដើរទៅកាន់ ភ្នំនិងព្រៃ ។ កាលបើដូច្នោះ ម្រឹគទាំងឡាយឃើញទូលបង្គំជាខ្ញុំហើយតក់ស្លុត ដោយហេតុដូចម្តេច តើព្រះអង្គនឹងឲ្យទូលបង្គំជឿដោយហេតុដូចម្តេច?"*

## ស្តេចបីឡិយក្សត្រធានាបម្រើម្តាយឪពុកសុវណ្ណសាម

*លុះទ្រង់ព្រះសណ្តាប់ដូច្នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ៖*

*"អាត្មាអញច្រុលច្រួសបាញ់មនុស្សឥតកំហុសនេះហើយ ថែមទាំងនិយាយកុហកទៀត, អញនឹងនិយាយតែពាក្យពិតតែម៉្យាងវិញ" ។*

*ហើយទ្រង់ត្រាស់ថា ៖*

"ន តំ តស មិគោ សាម  កិំ តាហំ អលិកំ ភណេ
កោធលោភាភិភូតាហំ  ឧសុំ តេ តំ អវស្សជី" ។

"ម្នាលសាម ម្រឹគមិនមែនផ្អើលនឹងអ្នកទេ អ្នកមានទស្សនៈល្អ យ៉ាងនេះ ខ្ញុំនឹងនិយាយកុហកអ្នកធ្វើអ្វី ខ្ញុំមានសេចក្ដីក្រោធ និង មានសេចក្ដីលោភគ្របសង្កត់ ទើបបាញ់អ្នកដោយព្រួញដូច្នេះ" ។

ពិតណាស់ ដំបូងឡើយ ម្រឹគមកប្រាកដពីមុខព្រះភក្ត្រព្រះរាជា ព្រះរាជាក៏លើកធ្នូឡើងដើម្បីបាញ់ម្រឹគ ដោយសេចក្ដីក្រោធ ភ្លាមនោះស្រាប់តែទតឃើញសុវណ្ណសាមពោធិសត្វ ព្រះអង្គមិនដឹងថា ជាទេវតា ឬជាអ្វីទេ ទ្រង់ញាំងលោភៈឲ្យកើតឡើងដោយព្រះតម្រិះថា ព្រះអង្គនឹងបាញ់សុវណ្ណសាម ព្រោះហេតុនោះ ទើបព្រះរាជាទ្រង់ត្រាស់ដូច្នោះ ។ លុះពោលយ៉ាងនេះហើយ ទ្រង់មានព្រះតម្រិះទៀតថា ៖

"សុវណ្ណសាមនេះ មិនមែនរស់នៅក្នុងព្រៃតែម្នាក់ឯងទេ, ប្រាកដជាមានពួកញាតិរស់នៅជាមួយដែរ, អញនឹងសួរគេមើល" ។

រួចទ្រង់ត្រាស់សួរទៀតថា ៖

"កុតោ នុ សាម អាគម្ម ကស្ស វា បហិតោ តុវំ
ឧទហារោ នទឹ គច្ឆ អាគតោ មិគសម្មតំ" ។

"ម្នាលសាម តើអ្នកមកអំពីទីណា ទើបបានមកដល់ព្រៃនេះ ?
ឬនរណាប្រើអ្នកមកដងទឹកនៅស្ទឹងមិគសម្មតានេះ ?"

សុវណ្ណសាមពោធិសត្វស្តាប់ព្រះរាជឱង្ការរបស់ព្រះរាជាហើយ លោកប្រឹងអត់សង្កត់ទប់ទល់នឹងទុក្ខវេទនាដ៏ខ្លាំងក្លា ក្រាបទូលព្រះរាជាទាំងមានឈាមហូរតាមមាត់ថា ៖

"អន្ធា មាតាបិតា មយ្ហំ តេ ភរាមិ ព្រហាវនេ
តេសាហំ ឧទកាហារោ អាគតោ មិគសម្មតំ" ។

"មាតាបិតារបស់ទូលបង្គំជាមនុស្សខ្វាក់ភ្នែក ទូលបង្គំជាខ្ញុំតែងរកមើមឈើផ្លែឈើជាដើមមកចិញ្ចឹមពួកគាត់ក្នុងព្រៃធំ ទូលបង្គំជាខ្ញុំជាអ្នកដងទឹកបម្រើអ្នកមានគុណ ទូលបង្គំមកស្ទឹងមិគសម្មតានេះដើម្បីដងទឹក" ។

លុះពោលយ៉ាងនេះហើយ ព្រះមហាសត្តពិលាបប្រារព្ធទៅនឹងម្តាយឪពុកថា ៖

"អត្ថិ នេសំ ឧសាមត្តំ អថ សាហស្ស ជីវិតំ
ឧទកស្ស អលាភេន មញ្ញេ អន្ធា មរិស្សរេ ។
ន មេ ឥទំ តថា ទុក្ខំ លព្ភា ហិ បុមុនា ឥទំ
យញ្ច អម្មំ ន បស្សាមិ តំ មេ ទុក្ខតរំ ឥតោ ។
ន មេ ឥទំ តថា ទុក្ខំ លព្ភា ហិ បុមុនា ឥទំ
យញ្ច តាតំ ន បស្សាមិ តំ មេ ទុក្ខតរំ ឥតោ ។

សា នូន កបណា អម្មា ចិររត្តាយ រុច្ចតិ
អឌ្ឍរត្តេវ រត្តេ វា នទីវ អវសុច្ចតិ ។
សោ នូន កបណោ តាតោ ចិររត្តាយ រុច្ចតិ
អឌ្ឍរត្តេវ រត្តេ វា នទីវ អវសុច្ចតិ ។
ឧដ្ឋានបាទចរិយាយ បាទសម្ពាហនស្ស ច
សាម តាតវិលបន្តា ហិណ្ឌិស្សន្តិ ព្រហាវនេ ។
ឥទម្បិ ទុតិយំ សល្លំ កម្បេតិ ហទយំ មមំ
យញ្ច អន្ធេ ន បស្សាមិ មញ្ញេ ហិស្សាមិ ជីវិតំ" ។

"ម៉ែះសមម្ដាយឪពុកទូលព្រះបង្គំជាខ្ញុំ មានត្រឹមតែភោជនបរិភោគប៉ុណ្ណោះ ឥតមានទឹកផឹកទេ បើយ៉ាងនេះ ជីវិតពួកគាត់អាចរស់នៅបានត្រឹមតែ ៦ ថ្ងៃទៀតប៉ុណ្ណោះ ដោយទទួលទានតែផ្លែឈើតូចធំដែលខ្ញុំបានបេះមកនៅសេសសល់ ដោយសារតែពួកគាត់ខ្វាក់ភ្នែក មុខជានឹងដាច់ទឹកស្លាប់ជាក់ជាពុំខាន ។ ដូច្នេះ ពុំមែនតែទូលបង្គំជាខ្ញុំម្នាក់ប៉ុណ្ណោះទេ ដែលត្រូវទទួលទុក្ខដ៏សែនខ្លោចផ្សានេះ ។ ទុក្ខខ្លាំងជាងនេះទៅទៀត ត្រង់ដែលទូលបង្គំជាខ្ញុំ ខានបានឃើញម្ដាយឪពុកទូលបង្គំ ។ ឱម៉ែះសមលោកទាំងពីរនៅកំព្រាទួញយំទាំងអធ្រាត្រនិងពេលជិតភ្លឺ អស់កាលយូរអង្វែងមុខជានឹងរីងស្ងួតដូចស្ទឹងក្នុងរដូវប្រាំងពុំខាន ។ បពិត្រព្រះរាជា

មួយវិញទៀត ទូលបង្គំតែងក្រវើនក្រតើនបម្រើបាទាដោយការ គក់ប្រាប់ នួតដៃដើងរបស់អ្នកម្ដាយលោកឪពុក ដោយសេចក្ដី ឧស្សាហ៍ ពីរបីដង មិនថាពេលយប់ឬពេលថ្ងៃ ។ ម៉្លេះសមលោក ទាំងពីរមិនយល់ទូលបង្គំនៅក្បែរឥឡូវនេះ នឹងដើរចរច្រប់[២៦] ទាំង ងងឹតភ្នែកក្នុងព្រៃធំ ដង្ហោយហៅរកទូលបង្គំថា សាមកូន ៗ ដូច្នេះពុំខានឡើយ ពួកលោកមើលទៅត្រូវបន្ទាមុតហើយ ។ ការ ដែលទូលបង្គំជាខ្ញុំខានឃើញម្ដាយឪពុកខ្វាក់ទាំងពីរនាក់នោះ ការណ៍នេះចាត់ទុកជាសរទីពីរដែលមុតបេះដូងរបស់ទូលព្រះ បង្គំជាខ្ញុំ ឲ្យកាន់តែពើតចុកចាប់ខ្លាំងក្លា រាប់រយ រាប់ពាន់ រាប់ សែនដង រងទុក្ខវេទនាជាងព្រួញពិសទី ១ ទៅទៀត ជីវិតទូលបង្គំ ជាខ្ញុំ មុខជាវិនាសជាក់ជាពុំខាន" ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ការពិលាបរបស់ព្រះមហាសត្តហើយ ទ្រង់ ព្រះចិន្ដាថា ៖

"សុវណ្ណសាមនេះ ជាអ្នកប្រព្រឹត្តនូវព្រហ្មចរិយធម៌យ៉ាងពេញ លេញ ឋិតនៅក្នុងធម៌ចិញ្ចឹមម្ដាយនិងឪពុក, ថ្វីបើឥឡូវនេះ គេ

---

[២៦] (កិ.), (កិ. វិ.) (ចច្រប់) ដើរចុះដើរឡើងសុសសព្វ (ដូចជាគេច្រប់អន្ទង់), ដើរវក់វី សព្វ : ដើរចរច្រប់ ។ ដើរចរច្រប់អារ៉ប់ គឺដើរចរច្រប់បត់ចុះបត់ឡើងច្រើនបកច្រើន សា ។

ដល់នូវសេចក្តីឈឺចាប់យ៉ាងនេះហើយ ក៏នៅតែពិលាបរកម្តាយឪពុក, អញធ្វើកំហុសចំពោះមនុស្សដែលដល់ព្រមដោយគុណសម្បត្តិយ៉ាងនេះ គួរបើដែរទេ, តើមានទមធ្យោបាយណាដែលអញគប្បីលួងលោមសុវណ្ណសាមនេះ?"

ព្រះអង្គមានព្រះរាជតម្រិះដូច្នេះរួច ទ្រង់ធ្វើសេចក្តីសន្និដ្ឋានដោយព្រះអង្គឯងថា ៖

"ដោយបាបកម្មនេះ អញនឹងធ្លាក់ទៅឆេះក្នុងនរក តើរាជសម្បត្តិនឹងជួយអញដូចម្តេចបាន, អាត្មាអញនឹងទំនុកបម្រុងម្តាយឪពុករបស់សុវណ្ណសាម ឲ្យដូចដែលសុវណ្ណសាមធ្លាប់ទំនុកបម្រុងមកហើយ, កាលបើដូច្នេះ ការស្លាប់របស់សុវណ្ណសាមនេះ ហាក់ដូចជាមិនស្លាប់" ។

មានព្រះរាជតម្រិះដូច្នេះហើយ ទ្រង់ត្រាស់ថា ៖

"មា ពាឡ្ហំ បរិទេវេសិ សាម កល្យាណទស្សន
អហំ កម្មករោ ហុត្វា ភរិស្សំ តេ ព្រហាវនេ ។
ឥស្សត្ថេ ចស្មិ កុសលោ ទឡ្ហធម្មោតិ វិស្សុតោ
អហំ កម្មករោ ហុត្វា ភរិស្សំ តេ ព្រហាវនេ ។

មិគានំ វិឃាសមន្វេសំ    វនមូលផលានិ ច
អហំ កម្មករោ ហុត្វា    ករិស្សំ តេ ព្រហាវនេ ។
កាតមំ តំ វនំ សាម    យត្ថ មាតាបិតា តវ
អហំ តេ តថា ករិស្សំ    យថា តេ អករី តុវំ” ។

*“ម្នាលសាម ជាអ្នកមានរូបល្អ គួរឲ្យគយគន់ អ្នកកុំខ្សឹកខ្សួលខ្លាំងពេកឡើយ ខ្ញុំសូមជានាធ្វើកិច្ចការសព្វសារពើ ចិញ្ចឹមម្ដាយឪពុករបស់អ្នកក្នុងព្រៃធំ ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូស្រាប់ មានឈ្មោះល្បីល្បាញថាជាខ្មាន់ធ្នូដ៏ស្ទាត់ជំនាញ ខ្ញុំសូមប្ដេជ្ញាចិញ្ចឹមម្ដាយឪពុករបស់អ្នកក្នុងព្រៃធំ ។ ខ្ញុំនឹងជាអ្នកធ្វើការងារស្វែងរករំពា[២៧]នៃម្រឹគនិងមើមឈើផ្លែឈើទាំងឡាយក្នុងព្រៃ ហើយនឹងចិញ្ចឹមម្ដាយឪពុករបស់អ្នកក្នុងព្រៃធំ ដោយការបាញ់ម្រឹគជាត់ ៗ មកចិញ្ចឹមម្ដាយឪពុករបស់អ្នកដោយរសជាតិសាច់ដ៏ផ្អែម”។*

*សុវណ្ណសាមទូលថា ៖*

---

[២៧] *ន.) ភក្សាហារដែលសត្វកាចពិឃាតបានហើយស៊ីខ្លះរួចទុកដោយហួងហែងបម្រុងនឹងស៊ីតទៅទៀត : រំពាខ្លា, ខ្លាការរំពា ។ ព. ប្រ. កំណាន់ចិត្ត (ស្ត្រីឬបុរសជាកំណាន់ចិត្ត) : ការរំពា, ក្រវែលរំពា ។*

"កុំឡើយមហាបពិត្រ កុំសម្លាប់សត្វមានជីវិត ដោយសារតែពួកទូលបង្គំឡើយ" ។

ព្រះរាជាក៏ត្រាស់ថា៖

"ម្នាលសាម តើម្ដាយឪពុករបស់អ្នកនៅក្នុងព្រៃណា? ព្រៃនោះដូចម្ដេច? អ្នកបានចិញ្ចឹមម្ដាយឪពុករបស់អ្នកយ៉ាងណា ខ្ញុំក៏នឹងចិញ្ចឹមពួកគាត់យ៉ាងនោះដែរ" ។

គ្រានោះ ព្រះមហាសត្តក្រាបទូលព្រះរាជាថា ៖

"ប្រពៃណាស់ មហាបពិត្រ, បើដូច្នោះ សូមព្រះអង្គចិញ្ចឹមម្ដាយនិងឪពុករបស់ទូលព្រះបង្គំជាខ្ញុំ ឲ្យទានផង"

រួចសុវណ្ណសាមក្រាបទូលប្រាប់ផ្លូវចំពោះទ្រង់ថា ៖

"អយំ ឯកបទី រាជ យោយំ ឧស្សីសកោ មម
ឥតោ គន្ត្វា អឌ្ឍកោសំ តត្ថ នេសំ អគារកំ
យត្ថ មាតាបិតា មយ្ហំ តេ ភរស្សុ ឥតោ គតោ" ។

"បពិត្រព្រះរាជា នៅខាងក្បាលដំណេកទូលបង្គំជាខ្ញុំ មានផ្លូវច្រើរដើងមួយខ្សែ ព្រះអង្គយាងទៅពីទីនេះតែកន្លះកោសៈ នឹងឃើញខ្ទមជាលំនៅរបស់ម្ដាយឪពុកទូលបង្គំជាខ្ញុំ សូមព្រះអង្គយាងទៅពីទីនេះ សូមទ្រង់ចិញ្ចឹមពួកគាត់ក្នុងទីនោះផង" ។

សុវណ្ណសាម លុះពិពណ៌នាថ្វាយទូលព្រះរាជាយ៉ាងនេះហើយ ក៏ខំប្រឹងអត់សង្កត់នូវក្តីឈឺចាប់ចុកពឹតបែបនោះ ។ ដោយសារសេចក្តី ស្រឡាញ់ខ្លាំងចំពោះម្តាយឪពុក លោកក៏ផ្គងអញ្ជលីសូមឲ្យស្តេចទ្រង់ចិញ្ចឹមនូវម្តាយឪពុកខ្លួន ដោយពោលបន្ថែមយ៉ាងនេះ ៖

"នមោ តេ កាសិរាជត្ថុ　　នមោ តេ កាសិវឌ្ឍន
អញ្ជលឹ តេ បគ្គណ្ហាមិ　　កាសិរាជ នមត្ថុ តេ
អន្ធា មាតាបិតា មយ្ហំ　　តេ ភរស្សុ ព្រហាវនេ ។
មាតរំ បិតរំ មយ្ហំ　　វុត្តោ វជ្ជាសិ វន្ទនំ" ។

"បពិត្រព្រះរាជាជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះរាជា ទ្រង់មានសេចក្តីចម្រើនក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ ម្តាយឪពុកទូលបង្គំជាខ្ញុំជាមនុស្សខ្វាក់ សូមទ្រង់ចិញ្ចឹមពួកគាត់ក្នុងព្រៃធំ ឲ្យទានផង ។ ទូលបង្គំ សូមផ្គងអញ្ជលីចំពោះព្រះអង្គ បពិត្រព្រះរាជាជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ ទូលបង្គំជាខ្ញុំសូមផ្តាំឲ្យទ្រង់ជម្រាបនូវការថ្វាយបង្គំរបស់ទូលបង្គំចំពោះម្តាយឪពុកទូលបង្គំជាខ្ញុំផងថា សុវណ្ណសាមកូនលោកត្រូវសរពិសមុតនៅក្បែរឆ្នេរស្ទឹង ដេកផ្អៀងខាងស្តាំ នៅលើពំនូកខ្សាច់ចាំងផ្ទេកដូចផ្ទាំងប្រាក់ កំពុងផ្គងអញ្ជលីថ្វាយបង្គំបាទាលោកទាំងពីរ" ។

ព្រះរាជា ស្ដេចទ្រង់ទទួលនូវសេចក្ដីស្នើនោះ ។ ចំណែកសុវណ្ណសាម កំលោះអ្នកមានរូបល្អគួរពិតពិលរមិលមើល លុះបានផ្ដាំផ្ញើការថ្វាយបង្គំរបស់ខ្លួនដល់ម្ដាយឪពុកហើយ ក៏សន្ទប់បាត់ស្មារតី ដោយកម្លាំងពិសដ៏ខ្លាំងក្លាជ្រាបចូលពេញខ្លួន ។

**អំណាត់សម្គាល់**

ពិតណាស់ កាលដែលសុវណ្ណសាម ពោលពាក្យបានប៉ុណ្ណោះ ក៏ដល់សភាពហាក់ដូចជាឥតមានដង្ហើមចេញចូល ។ ប៉ុន្តែបើនិយាយពីតំណនៃកវដ្តចិត្តរបស់លោកវិញ ដែលប្រព្រឹត្តទៅអាស្រ័យនឹងហទយរូបវិញ គឺមានកម្លាំងខ្សោយ ព្រោះឥទ្ធិពលពិសជ្រាបពេញខ្លួននាពេលនោះ ។ ដូច្នោះហើយ សម្ដីក៏ដាច់ឈប់និយាយ, មាត់បិទ, ភ្នែកបិទ, ដៃជើងរឹង, រាងកាយទាំងមូលស្ដូកស្ដឹង ប្រឡាក់ដោយឈាម ។

ព្រះរាជាពិចារណាខ្យល់ដង្ហើមចេញចូលរបស់សុវណ្ណសាមថា តើសុវណ្ណសាមនេះមានរឿងអ្វីកើតឡើង អម្បាញ់មិញគេនិយាយនឹងអញសោះ ។ ធម្មតា មនុស្សស្លាប់តែងមានរាងកាយរឹង ។ ព្រះរាជាទតឃើញស្ថានភាពដូច្នោះ ទ្រង់មិនអាចទប់សេចក្ដីសោកស្ដាយបាន ក៏លើកព្រះហស្តទាំងពីរ តម្កល់លើព្រះសីសៈ ស្រែកខ្សឹកខ្សួលខ្លាំង ៗ

ថា "ឥឡូវសាមស្លាប់ហើយ ៗ" ។ ព្រះរាជាទ្រង់ព្រះកន្សែងរៀបរាប់ដោយសេចក្តីករុណា និងសង្វេគក្នុងព្រះទ័យថា ៖

"ស រាជា បរិទេវេសិ        ពហុំ ការុញ្ញសញ្ហិតំ
អជរាមរោហំ អាសិំ        អជ្ជេតំ ញាមិ នោ បុរេ
សាមំ កាលង្កតំ ទិស្វា        នត្ថិ មច្ចុស្ស នាគមោ ។
យស្សុ មំ បដិមន្តេតិ        សវិសេន សមប្បិតោ
ស្វជ្ជ ឯវំ គតេ កាលេ        ន កិញ្ចិមភិភាសតិ ។
និរយំ នូន គច្ឆាមិ        ឯត្ថ មេ នត្ថិ សំសយោ
តទា ហិ បកតំ បាបំ        ចិររត្តាយ កិព្វិសំ ។
ភវន្តិ តស្ស វត្តារោ        គាមេ កិព្វិសការកោ
អរញ្ញេ និម្មនុស្សម្ហិ        កោ មំ វត្តុមរហតិ ។
សារយន្តិ ហិ កម្មានិ        គាមេ សំគច្ច មាណវា
អរញ្ញេ និម្មនុស្សម្ហិ        កោ នុ មំ សារយិស្សតិ" ។

"កន្លងមក អញតែងយល់ថា "អញមិនទាន់ចាស់ នឹងមិនស្លាប់" តែថ្ងៃនេះអញឃើញសុវណ្ណសាមស្លាប់ ទើបអញយល់យ៉ាង

ប្រចក្ស[២៨] ថា សេចក្ដីស្លាប់មានមែន មិនមែនទាល់តែចាស់ទើបបានស្លាប់នោះទេ ខ្លួនអញក្ដី អ្នកដទៃក្ដី គ្មានរឿងអ្វីដែលថាសេចក្ដីស្លាប់មិនមកដល់ ថ្ងៃនេះ អញដឹងដំណើរមកនៃសេចក្ដីស្លាប់ហើយ ពី ដើមឡើយ អញមិនដឹងថាសេចក្ដីស្លាប់មានសភាពដូច្នេះសោះ ។ ថ្ងៃនេះ សាមដែលថ្នាំពិសចូលជ្រួតជ្រាបពេញខ្លួន កំពុងចរចាជាមួយនឹងអញអម្បាញ់មិញនេះសោះ ឥឡូវស្រាប់តែនិយាយពាក្យអ្វីបន្ដិចបន្តួចលែងកើតទៀតហើយ ។ អញមុខជានឹងទៅកាន់នរកពុំខាន ឥតមានសេចក្ដីសង្ស័យក្នុងដំណើរនេះទេ ព្រោះថាអំពើបាបដែលអញធ្វើទុកហើយក្នុងគ្រានេះ នឹងជាទោសឲ្យផលដ៏លាមកឃោរឃៅក្ដៅឈឺផ្សាអស់កាលជាអង្វែង ។ បើក្នុងស្រុកវិញ គង់មានពួកអ្នកតិះដៀលអញថា "អញជាអ្នកធ្វើអំពើអាក្រក់បែបនេះ" តែក្នុងព្រៃដែលឥតមនុស្សតើមាននរណាតិះដៀល អញ ? បើមានមែន ចូរតិះដៀលខ្ញុំមកចុះ ។ បើក្នុងស្រុក ឬនិគមវិញ គង់មានមនុស្សម្នាប្រជុំគ្នាចោទប្រកាន់នូវអំពើរបស់អញថា អញធ្វើអំពើមនុស្សឃាត ប្រព្រឹត្តអំពើឃោរឃៅ សមដាក់ទោសទណ្ឌបែបនេះ បែបនោះពុំខាន

[២៨] (កិ. វិ.), (គុ.) ដែលជាក់, ប្រាដក, ច្បាស់, មែន, ពិត : ហេតុប្រចក្ស គឺហេតុដែលប្រាកដ; ឃើញប្រចក្ស គឺឃើញច្បាស់; ដឹងប្រចក្ស គឺដឹងជាក់; មនុស្សប្រត្យក្ស គឺមនុស្សអ្នកដឹងកិច្ចការជាក់ ។

តែក្នុងព្រៃដែលឥតមនុស្ស តើនឹងមាននរណាចោទប្រកាន់
អញ?"

## ទេពធីតាពហុសុន្ទរី

គ្រានោះ ទេវធីតាមួយអង្គនាមថា **ពហុសុន្ទរី** អាស្រ័យនៅឯភ្នំគន្ធមាទន៍ ដែលធ្លាប់ជាម្តាយរបស់ព្រះមហាសត្ត ក្នុងអត្តភាពទី ៧ រាប់ពីជាតិសុវណ្ណសាមនេះថយក្រោយ ។ ទេវធីតានោះ ព្រោះហេតុតែស្រឡាញ់កូន ក៏តែងចាំឃ្លាំមើលរក្សានូវសុវណ្ណសាមពោធិសត្វជានិច្ច ប៉ុន្តែ ក្នុងថ្ងៃនោះ ដោយជាប់រវល់ក្នុងការសោយទិព្វសម្បត្តិ ក៏មិនបានចាំឃ្លាំមើល ។ អាចារ្យខ្លះនិយាយថា "ព្រះនាងរវល់ទៅកាន់ទេវសមាគម" ។ លុះដល់ពេលដែលសុវណ្ណសាមសន្លប់បាត់មាត់ឈឹងនោះ ទើបព្រះនាងរំពឹងមើល ក៏បានដឹងច្បាស់ថា "ព្រះរាជានាមបីឡិយក្សនេះបានបាញ់កូនអញដោយព្រួញពិស ធ្វើឲ្យគេដួលស្លាប់លើពំនូកខ្សាច់ទៀបឆ្នេរស្ទឹងមិគសម្មតា រួចហើយទ្រង់បែរជាស្រែកខ្សឹកខ្សួលខ្លាំងៗទៅវិញ, បើអញមិនទៅជួយទេ, សុវណ្ណសាមកូនរបស់អញ ប្រាកដជាស្លាប់ក្នុងទីនោះមិនខាន ។ ឯព្រះរាជាក៏នឹងបែកហឫទ័យ ចំណែកម្តាយឪពុករបស់សាម នឹងអត់អាហារ អត់ទឹក រហូតដល់ស្លាប់ដែរ ។ តែបើអញទៅដល់ទីនោះ, ស្តេចនឹងកាន់យកក្អមទឹកទៅកាន់សម្នាក់របស់ម្តាយឪពុកសុវណ្ណសាម លុះទៅដល់ហើយស្តេចនឹងប្រាប់ម្តាយឪពុក

សាមថា "កូនរបស់លោក ត្រូវបានយើងបាញ់សម្លាប់ហើយ", លុះប្រាប់យ៉ាងនេះ ស្តេចនឹងបានស្តាប់ពាក្យពេចន៍របស់ម្តាយឪពុកសាម ហើយនឹងនាំម្តាយឪពុកសាមមកកាន់ទីកន្លែងដែលសាមដេកដួលនៅ, កាលបើដូច្នេះ ទាំងម្តាយឪពុកសាម ទាំងអញ នឹងធ្វើសច្ចកិរិយា កម្លាំងពិសក្នុងខ្លួនសាមនឹងសាបរលាបដោយអានុភាពនៃសច្ចវាចានោះ, កាលបើយ៉ាងនេះ កូនអញនឹងរួចផុតពីគ្រោះថ្នាក់ រស់រានមានជីវិតវិញ ។ រីឯម្តាយឪពុករបស់សាម នឹងមានភ្នែកភ្លឺឡើងវិញ ទាំងព្រះរាជា ក៏នឹងបានស្តាប់នូវធម្មទេសនារបស់សុវណ្ណសាម លុះទ្រង់យាងត្រឡប់ទៅកាន់នគរវិញ នឹងចំណាយទ្រព្យធ្វើទានជាច្រើន មានឋានសួគ៌ជាគតិសន្សឹម ព្រោះដូច្នោះ អញត្រូវតែទៅកាន់ទីនោះឲ្យខាងតែបាន" ។ រំពេចនោះ ទេពធីតាក៏បាត់ខ្លួនពីភ្នំគន្ធមាទន៍ ទៅឈរឰដ៏អាកាសដោយកាយមិនប្រាកដ ទៀបឆ្នេរស្ទឹងមិគសម្មតា ថ្លែងវាចាជាមួយនឹងព្រះរាជាថា ៖

"អាគុំ កិរ មហារាជ　　　អការិ កម្មទុក្កដំ
អទូសកា បិតាបុត្តា　　　តយោ ឯកូសុនា ហតា ។
ឯហិ តំ អនុសិក្ខាមិ　　　យថា តេ សុគតី សិយា
ធម្មេនន្ធេ វនេ បោស　　　មញ្ញេហំ សុគតី តយា" ។

"បពិត្រមហារាជ ឮថា ព្រះអង្គបានធ្វើនូវបាបកម្មដ៏ធ្ងន់លាមក

អាក្រក់ក្រៃលែង ព្រោះព្រះអង្គបានសម្លាប់ជនគ្មានកំហុស ៣ នាក់គឺម្តាយ ឪពុក និងកូន ឲ្យអស់ជីវិតដោយព្រួញតែមួយពិតណាស់ កាលបើសាមស្លាប់ ម្តាយឪពុកសាមក៏ឈ្មោះថាស្លាប់ដែរ ព្រោះជីវិតលោកទាំងពីរពឹងផ្អែកលើសាមយ៉ាងសំខាន់ ។ សូមទ្រង់យាងមក ខ្ញុំម្ចាស់នឹងថ្វាយយោបល់ ដើម្បីញ៉ាំងព្រះអង្គឲ្យបានទៅសុគតិភព គឺសូមទ្រង់ចិញ្ចឹមថែទាំជនខ្វាក់ទាំងពីរនាក់នោះដោយធម៌ ដូចដែលសុវណ្ណសាមធ្វើសព្វដង ខ្ញុំម្ចាស់យល់ថាសុគតិនឹងគប្បីមានដល់ព្រះអង្គពុំខាន ដោយវិធីនេះ" ។

## ស្តេចបីឡិយក្សយកទឹកជូនម្តាយឪពុកសុវណ្ណសាម

ព្រះរាជាអង្គនោះ បានសណ្តាប់ ហើយជឿតាមពាក្យរបស់ទេពធីតា រួចទ្រង់ព្រះតម្រិះដោយតាំងព្រះទ័យយ៉ាងមាំថា កាលអញចិញ្ចឹមម្តាយឪពុករបស់សាមដោយល្អហើយ អញនឹងបានទៅកាន់ស្ថានសួគ៌ព្រោះថា រាជសម្បត្តិគ្មានប្រយោជន៍អ្វីដល់អញឡើយ ។ ស្តេចអង្គនេះមានវិប្បដិសារៈនិងខ្សឹកខ្សួលអួលអាក់យ៉ាងខ្លាំងឥតស្រាកស្រាន្ត លុះបន្ទោបង់សេចក្តីសោក ដកដង្ហើមធូរហើយ ដោយយល់ថាសាមស្លាប់ក៏ទ្រង់កាច់ផ្កានានាមកបូជាសរីរៈសុវណ្ណសាម ស្រោចស្រពដោយសុគន្ធវារី (ទឹកអប់ផ្កា) ធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំទិសទាំង ៤ ។

ហើយទ្រង់កាន់ក្អមដែលសុវណ្ណសាមដងទឹកដាក់ពេញស្រាប់នោះ យាងឆ្ពោះទៅត្រង់ទិសខាងត្បូងតាមការចង្អុលប្រាប់របស់សុវណ្ណសាម ទាំងព្រះទ័យស្រពាប់ស្រពោន ។

តាមប្រក្រតីរបស់ព្រះរាជា មានឥរិយាបថបោះជំហានព្រះបាទាធ្ងន់ ៗ មិនសូវបេះថ្នមព្រះបាទ ។ ព្រះរាជាកាន់ក្អមទឹក យាងចូលទៅក្នុងអាស្រមបទ ឮសូរហាក់ដូចជាតន្ត្រី, កាលយាងដល់ទ្វារបណ្ណសាលារបស់ទុកូលតាបស ពេលនោះទុកូលតាបសកំពុងអង្គុយខាងក្នុង ឮស្នូរជើង ក៏លាន់មាត់ថា "នេះមិនមែនស្នូរជើងសាមទេ, តើនរណាហ្នុំ ?" ហើយគាត់សួរថា ៖

"កស្ស នុ ឯសោ បទសទ្ទោ មនុស្សស្សេវ អាគតោ
នេសោ សាមស្ស និគ្ឃោសោ កោ នុ ត្វមសិ មារិស ។
សន្តញ្ហិ សាមោ វជតិ សន្តំ ចានានិ នេយតិ
នេសោ សាមស្ស និគ្ឃោសោ កោ នុ ត្វមសិ មារិសា" ។

"សូរជើងនរណាដែលដើរមកនេះ មិនមែនសូរជើងតោ ខ្លាធំ ខ្លាដំបង យក្ស នាគ ឬកិន្នរទេ ពិតជាសូរជើងមនុស្ស តែមិនមែនសូរជើងសាមទេ ។ ម្នាលអ្នកនិរទុក្ខ[២៩] អ្នកជានរណា ? ដ្បិតសាម

[២៩] ដែលឥតទុក្ខ, ឥតព្រួយ ។

កូនរបស់យើង តែងដើរថ្នមៗ លើកដាក់ជើងស្រាលៗ ។ សូរជើង
នុ៎ះ ពិតជាមិនមែនសូរជើងសាមកូនយើងទេ ម្នាលអ្នកនិរទុក្ខ
តើអ្នកជានរណា ? ចូរប្រាប់យើងឲ្យដឹងផង" ។

ព្រដូច្នោះ ព្រះរាជាទ្រង់ព្រះចិន្តាថា "ប្រសិនបើអញមិនប្រាប់ថា ខ្លួនជាស្តេចសិនទេ, ហើយប្រាប់ថាអញសម្លាប់កូនគាត់តែម្តង មុខជាពួកគាត់ក្រោធខឹង ហើយនឹងនិយាយពាក្យគ្រោតគ្រាតទ្រគោះបោះបោក ឬជេរប្រទេចអញ ។ អញនឹងក្រោធតបចំពោះពួកគាត់, កាលបើអញក្រោធខឹងតប អញអាចនឹងបៀតបៀនពួកគាត់, ដែលជាអំពើអកុសលរបស់អញកាន់តែច្រើនឡើង ។ ប៉ុន្តែកាលបើអញប្រាប់ថា ខ្លួនអញជាស្តេចផែនដី អ្នកណាក៏កោតខ្លាចដែរ, ព្រោះដូច្នោះ អញនឹងប្រាប់ថា អញជាស្តេចផែនដីជាមុន" ។ កាលស្តេចតម្កល់ក្អមទឹកលើជើងរង្វួច ទ្រង់មកឈរទៀបទ្វារបណ្ណសាលា មានព្រះរាជឱង្ការថា ៖

"រាជាហមស្មិ កាសីនំ		បីឡិយក្ខោតិ មំ វិទូ
លោភា រដ្ឋំ បហិត្វាន		មិគមេសំ ចរាមហំ ។
ឥស្សត្ថេ ចស្មិ កុសលោ		ទឡ្ហធម្មោតិ វិស្សុតោ
នាគោបិ មេ ន មុច្ចេយ្យ		អាគតោ ឧសុបាតនំ" ។

"យើងជាព្រះរាជារបស់ពួកអ្នកដែនកាសី គេហៅយើងថាបីឡិ-
យក្ស យើងលះបង់ដែន ត្រាច់ចរស្វែងរកម្រឹគ ព្រោះល្មោភ
សោយសាច់ ។ ម្យ៉ាងទៀត យើងជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ
មានឈ្មោះល្បីល្បាញថាជាខ្លាន់ធ្នូដ៏ស្ទាត់ជំនាញ ទ្រទ្រង់ធ្នូដ៏មាំ
សូម្បីដំរីមកចំពីមុខព្រួញរបស់យើងហើយ មិនអាចរួចរស់ជីវិត
បានទេ" ។

ចំណែកទុកូលតាបស ក៏ធ្វើបដិសណ្ឋារកិច្ចចំពោះព្រះរាជា ដោយ
ពោលពាក្យថា ៖

"ស្វាគតំ តេ មហារាជ អថោ តេ អទុរាគតំ
ឥស្សរោសិ អនុប្បត្តោ យំ ឥធត្ថិ បវេទយ ។
តិន្ទុកានិ បិយាលានិ មធុកេ កាសុមារិយោ
ផលានិ ខុទ្ទកប្បានិ ភុញ្ជ រាជ វរំ វរំ ។
ឥទម្បិ បានីយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ" ។

"បពិត្រមហារាជ ព្រះរាជដំណើរមករបស់ព្រះអង្គល្អហើយ
ព្រះរាជដំណើរមករបស់ព្រះអង្គមិនអាក្រក់ទេ ព្រះអង្គជាធំ
ទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មាន

ព្រះបន្ទូលចុះ ។ បពិត្រព្រះរាជា ផលាផលគឺផ្លែទន្ទាប់ មាក់ប៉ែន ស្រគំ សឹងមានរសផ្អែមឆ្ងាញ់ដូចទឹកឃ្មុំ អាត្មាភាពបានប្រមូលមក ទុកក្នុងទីជាមួយគ្នា ។ នេះទឹកត្រជាក់ដែលដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គស្ដេចទ្រង់សោយក្រសាលចុះ ក្រាបទូល" ។

សូមអ្នកអាន មើលសេចក្ដីនៃគាថានេះបន្ថែមនៅក្នុងសត្តិគុម្ពជាតក ។ ទឹកជ្រោះក្នុងទីនេះ គឺម្ដាយឪពុកសាមនិយាយសំដៅទឹកដែលសាមដងពីស្ទឹងមិគសម្មតា ព្បិតទឹកស្ទឹងនេះហូរមកពីជ្រោះភ្នំ ដូច្នេះ នឹងនិយាយថា ទឹកជ្រោះភ្នំ ក៏បាន ។

កាលបើទុកូលតាបសធ្វើបដិសណ្ឋារកិច្ចយ៉ាងនេះ ស្ដេចទ្រង់ព្រះចិន្ដាថា "ការដែលអញប្រាប់ជាមុនថា 'កូនរបស់លោកខ្ញុំសម្លាប់ហើយ' នេះមិនសមសោះ, ដូច្នេះអញត្រូវធ្វើដូចជាមិនដឹង ហើយសន្ទនាគ្នាសិន សឹមប្រាប់" រួចទ្រង់ត្រាស់សួរថា ៖

"នាលំ អន្ធា វនេ ទដ្ឋុំ      កោ នុ វោ ផលមាហរិ
អននុស្សេវយំ សម្មា      និវាតោ មយ្ហ ខាយតិ" ។

"លោកទាំងពីរជាមនុស្សខ្វាក់ មិនអាចមើលឃើញអ្វីក្នុងព្រៃទេ ចុះនរណាប្រមូលផលាផលទាំងនេះមកជូនលោក ?

ព្រោះអាហារផលាផលបរិសុទ្ធគួរទំពាដែលបានមកដោយផ្ចិតផ្ចង់នេះ ខ្ញុំមើលទៅដូចជាមិនមែនលោកទាំងពីរជាអ្នក (មនុស្សពិការភ្នែក)ប្រមូលមកទេ" ។

ព្ទដូច្នោះ ទុកូលតាបសទូលតបថា ៖

"បពិត្រមហារាជ ផលាផលនេះ មិនមែនពួកទូលបង្គំជាអ្នកប្រមូលមកខ្លួនឯងទេ គឺកូនរបស់ទូលបង្គំជាអ្នកប្រមូលមកទេតើ ក្រាបទូល" ។

ហើយគាត់បានទូលបន្តថា ៖

"ទហរោ យុវា នាតិព្រហា	សាមោ កល្យាណទស្សនោ
ទីឃស្ស កេសា អសិតា	អថោ សូនគ្គវេល្លិតា ។
សោ ហវេ ផលមាហរិត្វា	ឥតោ អាទាយ កមណ្ឌលុំ
នទឹ គតោ ឧទហារោ	មញ្ញេ ន ទូរមាគតោ" ។

"សាមកូនរបស់ទូលបង្គំនៅក្មេងមិនខ្ពស់ពេក មិនទាបពេក ជាមនុស្សមានរូបល្អ គួរគយគន់ មានសក់វែងខ្មៅស្រិលរលើបរលង់ទាំងមានចុងទន់ល្មៀយ ។ សាមនោះឯង តែងស្វែងរកផលាផលរួចបានកាន់ក្អមទៅដងទឹកនៅឯស្ទឹង ឥឡូវនេះប្រហែលជាជិតមកដល់វិញហើយ" ។

*ឮដូច្នោះ ព្រះរាជាទ្រង់ត្រាស់ថា ៖*

"អហំ តំ អវធឹ សាមំ        យោ តុយ្ហំ បរិចារកោ
យំ កុមារំ បវេទេថ        សាមំ កល្យាណទស្សនំ ។
ទីឃស្ស កេសា អសិតា        អថោ សូនគ្គវេល្លិតា
តេសុ លោហិតលិត្តេសុ        សេតិ សាមោ មយា ហតោ" ។

*"លោកនិយាយសំដៅកុមារឈ្មោះសាម ដែលមានរូបល្អគួរគយគន់ ហើយជាអ្នកបម្រើលោក សាមនោះ យើងបាញ់ស្លាប់ដោយសរពិសហើយ ។ សាម ដែលមានសក់វែង ពណ៌ខ្មៅ ចុងទន់ល្មើយ ឥឡូវនេះ យើងបាញ់ស្លាប់ ដួលដេកលើសក់ប្រឡាក់ដោយឈាម នៅលើពំនូកខ្សាច់ ក្បែរឆ្នេរស្ទឹងមិគសម្មតា" ។*

*នាងបារិកា អង្គុយនៅក្នុងបណ្ណសាលារបស់ខ្លួន ដែលនៅមិនឆ្ងាយពីទុកូលតាបស ក៏បានឮពាក្យព្រះរាជា ហើយចង់ដឹងព្រឹត្តិការណ៍នោះឲ្យកាន់តែច្បាស់ នាងចេញអំពីបណ្ណសាលារបស់ខ្លួន ដើរស្ទួតាមខ្សែទៅកាន់សម្នាក់របស់ទុកូលតាបស បានពោលថា ៖*

"កេន ទុកូល មន្តេសិ        ហតោ សាមោតិ វាទិនា
ហតោ សាមោតិ សុត្វាន        ហទយំ មេ បវេធតិ ។
អស្សត្ថស្សេវ តរុណំ        បវាឡំ មាលុតេរិតំ
ហតោ សាមោតិ សុត្វាន        ហទយំ មេ បវេធតិ" ។

*"បពិត្រទុកូល អ្នកប្រឹក្សាជាមួយនឹងនរណា ដែលនិយាយថា គេសម្លាប់សាមកូនយើង ។ បេះដូងខ្ញុំញាប់ញ័រចំប្រប់ ហាក់ដូចត្រួយពោធិ៍បាយ[៣០] ខ្ចី ត្រូវខ្យល់បោកបក់ ព្រោះឮថា សាមកូនយើងស្លាប់" ។*

*ទុកូលតាបស ឲ្យដំបូន្មាននាងបារិកាថា ៖*

"ចារិកេ កាសិរាជាយំ　　សោ សាមំ មិគសម្មតេ
កោធសា ឧសុនា វិជ្ឈិ　　តស្ស មា បាបមិច្ឆិម្ហា" ។

*"ម្នាលនាងបារិកា នេះជាព្រះរាជា ជាធំក្នុងដែនកាសី ព្រះអង្គបាញ់សាមនឹងព្រួញ ក្បែរឆ្នេរស្ទឹងមិគសម្មតាដោយសេចក្ដីក្រោធចំពោះម្រឹគ យើងទាំងពីរមិនចង់ឲ្យបាបកើតមានដល់ព្រះអង្គឡើយ" ។*

*នាងបារិកានិយាយទៀតថា ៖*

"កិច្ឆា លទ្ធោ បិយោ បុត្តោ　យោ អន្ធេ អភរី វនេ
តំ ឯកបុត្តំ ឃាតិម្ហិ　　កថំ ចិត្តំ ន កោបយេ" ។

---

[៣០] (ន.) (ពោ--) *អស្សត្ថព្រឹក្ស ។ ខ្មែរច្រើនហៅពោធិ៍មួយប្រភេទស្លឹកតូច ៗ ថា ពោធិ៍បាយ; ពោធិ៍ដែលមានស្លឹកធំ ៗ ច្រើនហៅថា ពោធិ៍ធំ ។*

"កូនប្រុសតែមួយ ជាទីស្រឡាញ់របស់យើង ជាអ្នកចិញ្ចឹមយើង ដែលងងឹតភ្នែកទាំងពីរនៅក្នុងព្រៃ ជាបុត្ររកបានដោយកម្រក្រៃណាស់ តើមិនឲ្យខ្ញុំរំជួលចិត្តខឹងចំពោះអ្នកសម្លាប់កូនតែមួយរបស់យើងដូចម្ដេចបាន ?"

ទុកូលតាបសតបថា ៖

"កិច្ឆា លទ្ធោ បិយោ បុត្តោ  យោ អន្ធេ អភរី វនេ
តំ ឯកបុត្តំ ឃាតិម្හិ  អក្កោធំ អាហុ បណ្ឌិតា" ។

"ម្នាលនាងបារិកា កូនបណ្ដូលចិត្តតែមួយរបស់យើង ត្រូវស្លាប់ដោយក្សត្របាញ់ក៏ពិតមែន ប៉ុន្តែបណ្ឌិតទាំងឡាយ តែងពោលសរសើរនូវសេចក្ដីមិនក្រោធតបថាជាគុណជាតិដ៏ឧត្តមថ្លៃថ្លាក្រៃលែង, ធម្មតា សេចក្ដីក្រោធ ជាទោសជាតិទាញឲ្យធ្លាក់នរក ព្រោះហេតុនោះ បណ្ឌិតទាំងឡាយពោលថា បុគ្គលមិនត្រូវធ្វើនូវសេចក្ដីក្រោធ ត្រូវធ្វើនូវសេចក្ដីមិនក្រោធឲ្យខានតែបាន ចំពោះអ្នកដែលសម្លាប់កូនរបស់ខ្លួន" ។

*លុះនិយាយយ៉ាងនេះហើយ តាបសទាំងពីរនាក់នោះ លើកដៃទាំងពីរគក់ទ្រូង ខ្សឹកខ្សួល ពោលរៀបរាប់អំពីគុណសម្បត្តិទាំងឡាយរបស់សុវណ្ណសាមយ៉ាងច្រើន ។ គ្រានោះ ព្រះរាជាលួងលោមតាបសទាំងពីរនាក់នោះថា ៖*

"មា ពាឡ្ហំ បរិទេវេថ        ហតោ សាមោតិ វាទិនា
អហំ កម្មករោ ហុត្វា        ភរិស្សាមិ ព្រហាវនេ ។
ឥស្សត្ថេ ចស្មិ កុសលោ     ទឡ្ហធម្មោតិ វិស្សុតោ
អហំ កម្មករោ ហុត្វា        ភរិស្សាមិ ព្រហាវនេ ។
មិគានំ វិឃាសមន្វេសំ        វនមូលផលានិ ច
អហំ កម្មករោ ហុត្វា        ភរិស្សាមិ ព្រហាវនេ" ។

*"អ្នកទាំងពីរ សូមកុំសោយសោកខ្សឹកខ្សួលខ្លាំងពេកឡើយ ចំពោះខ្ញុំដែលពោលថា សាមគឺខ្ញុំសម្លាប់ សូមកុំខ្សឹកខ្សួលថា កូនរបស់យើងបរិបូណ៌ដោយគុណសម្បត្តិយ៉ាងនេះ ត្រូវព្រះរាជាបាញ់ស្លាប់ តើឥឡូវនេះ នរណានឹងចិញ្ចឹមយើងដូច្នេះជាដើមឡើយ ។ ខ្ញុំនឹងជានាធ្វើការងារចិញ្ចឹមអ្នកទាំងពីរក្នុងព្រៃធំជំនួសសាម ព្រោះខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថាជាខ្មាន់ធ្នូដ៏ស្ទាត់ជំនាញ ខ្ញុំនឹងធ្វើការងារចិញ្ចឹមអ្នកទាំងពីរក្នុង*

ព្រៃធំ ៗ ខ្ញុំនឹងស្វែងរករំពាម្រឹគ មើមឈើ ផ្លែឈើទាំងឡាយ ហើយចិញ្ចឹមអ្នកក្នុងព្រៃធំ" ។

ព្រះរាជាលួងលោមជនទាំងពីរនាក់បន្ថែមថា ៖

"សូមអ្នកទាំងពីរ កុំគិតឡើយ, ខ្ញុំមិនត្រូវការរាជសម្បត្តិទៀតទេ, ខ្ញុំនឹងចិញ្ចឹមអ្នកទាំងពីររហូតអស់ជីវិត"

តាបសទាំងពីរសម្តែងសេចក្តីស្និទ្ធស្នាលជាមួយនឹងព្រះរាជា ហើយនិយាយថា ៖

"នេស ធម្មោ មហារាជ  នេតំ អម្ហេសុ កប្បតិ
រាជា ត្វមសិ អម្ហាកំ  ចាទេ វន្ទាម តេ មយំ" ។

"បពិត្រមហារាជ នេះមិនមែនជាទំនៀមទេ កិរិយាធ្វើនូវអំពើរបស់ព្រះអង្គនេះ មិនសមគួរ មិនល្អ ដល់ពួកទូលបង្គំឡើយ ព្រោះព្រះអង្គជាព្រះរាជារបស់ពួកទូលបង្គំ ៗ សូមថ្វាយបង្គំព្រះបាទារបស់ព្រះអង្គ" ។

តាបសទាំងពីរ ហេតុតែត្រូវសេចក្តីសោកស្តាយកូនគ្របសង្កត់ និងមានមានះដាក់ចុះ ទោះបីបិតក្នុងភេទបព្វជិតក៏ដោយ ក៏និយាយថា "សូមថ្វាយបង្គំព្រះបាទារបស់ព្រះរាជា" ។

កេចិអាចារ្យ (អាចារ្យខ្លះ) ពោលថា "តាបសទាំងពីរនិយាយយ៉ាង នោះ ដើម្បីញ៉ាំងសេចក្តីស្និទ្ធស្នាលរបស់ព្រះរាជាឲ្យកើតឡើង" ។ ទ្រង់សណ្តាប់ដូច្នោះហើយ ព្រះរាជាសព្វព្រះហឫទ័យត្រេកអរយ៉ាង ក្រៃលែង ទ្រង់ព្រះតម្រិះថា "ឱហ្ន៎! អស្ចារ្យអ្វីម៉្លេះ, លោកទាំងពីរនេះ មានគុណធម៌ខ្ពស់ណាស់ ពាក្យគ្រោតគ្រាតសូម្បីបន្តិចបន្តួចរបស់ពួក គាត់ ពុំមានសោះឡើយ មកលើអញដែលជាអ្នកធ្វើកំហុសដ៏ធ្ងន់យ៉ាង នេះ, ពួកគាត់នៅតែផ្គងអញ្ជលីចំពោះអញ" ហើយទ្រង់ក៏មានព្រះរាជ-ឱង្ការទៀតថា ៖

"ធម្មំ ភេសាទា ភណថ    កតា អបចិតី តយា
បិតា ត្វមសិ អម្ហាកំ    មាតា ត្វមសិ ចារិកេ" ។

"បពិត្រតាបសទាំងពីរ អ្នកពោលនូវធម៌និងធ្វើនូវសេចក្តីគោរព ចំពោះខ្ញុំ ខ្ញុំសូមទុកអ្នកទាំងពីរជាមាតាបិតារបស់ខ្ញុំ ចាប់តាំងពីថ្ងៃ នេះតរៀងទៅ" ។

គឺព្រះរាជាត្រាស់ចំពោះតាបសមួយ ៗ ថា បពិត្រលោកទុកូល តាបស តាំងពីថ្ងៃនេះទៅ សូមលោកឋិតក្នុងឋានៈជាព្រះបិតារបស់ខ្ញុំ ព្រះម៉ែម្ចាស់បារិកា សូមឋិតក្នុងឋានៈជាព្រះមាតារបស់ខ្ញុំ ចំណែកឯខ្ញុំ វិញ សូមឋិតក្នុងឋានៈរបស់សាមដែលជាកូនរបស់លោក ខ្ញុំនឹងធ្វើកិច្ច

ការសព្វសារពើ មានការលាងជើងជាដើម សូមកុំសម្គាល់ខ្ញុំថាជាព្រះរាជាឡើយ សម្គាល់ខ្ញុំថាជាសាមចុះ ។

## ម្ដាយឪពុកសុវណ្ណសាមតាំងសច្ចាធិដ្ឋាន

តាបសទាំងពីរនោះ ផ្គងអញ្ជលីថ្វាយបង្គំអង្វរព្រះរាជាថា ៖

> "បពិត្រមហារាជ ព្រះអង្គមិនចាំបាច់ធ្វើកិច្ចការងារចំពោះពួកទូលបង្គំទេ, សូមព្រះអង្គមេត្តាជួយកាន់ចុងឈើច្រត់ នាំពួកទូលបង្គំទៅជួបសាមផង" ។

ពួកតាបសពោលបន្តថា ៖

"នមោ តេ កាសិរាជត្ថុ  នមោ តេ កាសិវឌ្ឍន
អញ្ជលឹ តេ បគ្គណ្ហាម  យាវ សាមានុបាបយ ។
តស្ស បាទេ សមជ្ជន្តា  មុខញ្ច ភុជទស្សនំ
សំសុម្ភមានា អត្តានំ  កាលមាគមយាមសេ" ។

> "បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ពួកទូលបង្គំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គទ្រង់ចម្រើនក្នុងដែនកាសី ពួកទូលបង្គំសូមថ្វាយបង្គំព្រះអង្គ ទូលបង្គំទាំងឡាយ សូមប្រណម្យអញ្ជលី

ចំពោះព្រះអង្គ សាមនៅទីណា សូមព្រះអង្គនាំទូលបង្គំទៅជួប សាម នៅទីនោះ ។ ទូលបង្គំទាំងពីរ នឹងបានច្របាច់ជើង ស្ទាប មុខរបស់សាមដ៏ល្អផូរផង់ គួរពិតពិលរមិលមើល ទូលបង្គំទាំងពីរ ត្រៀមខ្លួនរង់ចាំតែសេចក្ដីស្លាប់ប៉ុណ្ណោះ" ។

កាលដែលជនទាំងនោះ កំពុងតែនិយាយគ្នាយ៉ាងនេះ សុរិយាក៏ទន់ទាបអស្ដង្គត ។ គ្រានោះ ព្រះរាជាមានព្រះតម្រិះថា ៖

"ប្រសិនបើអញនាំតាបសទាំងពីរនេះទៅទីនោះឥឡូវ, អ្នកទាំងពីរ នឹងបែកទ្រូងស្លាប់ជាក់ជាពុំខានឡើយ ព្រោះបានជួបនឹងស្ថាន-ភាពរបស់សុវណ្ណសាមនោះ, កាលបើជនទាំងបីនាក់នោះស្លាប់ អញប្រាកដជានឹងកើតក្នុងនរកមិនខាន, ព្រោះហេតុនោះ អញ មិនគួរនាំអ្នកទាំងពីរទៅជួបសុវណ្ណសាមទេ" ។

លុះព្រះតម្រិះដូច្នេះហើយ ស្ដេចបានពោលនូវគាថា ៤ នេះ ៖

"ព្រហា វាឡមិគាកិណ្ណំ អាកាសន្តំវ ទិស្សតិ
យត្ថ សាមោ ហតោ សេតិ ចន្ទោវ បតិតោ ឆមា ។
ព្រហា វាឡមិគាកិណ្ណំ អាកាសន្តំវ ទិស្សតិ
យត្ថ សាមោ ហតោ សេតិ សូរិយោវ បតិតោ ឆមា ។
ព្រហា វាឡមិគាកិណ្ណំ អាកាសន្តំវ ទិស្សតិ

យត្ថ សាមោ ហតោ សេតិ  បំសុនា បតិកុន្ថិតោ ។
ព្រហា វាឡមិគាកិណ្ណំ  អាកាសន្តំវ ទិស្សតិ
យត្ថ សាមោ ហតោ សេតិ  ឥធេវ វសេថស្សមេ" ។

"សាមបានដួលដេកស្លាប់ក្នុងព្រៃស្រោងស្រឹង ដូចជាព្រះចន្ទធ្លាក់ចុះលើប្រឹថពី ព្រៃនោះសឹងសម្បូរដោយម្រឹគីម្រឹគាកាចសាហាវ ថែមទាំងនៅឆ្ងាយដូចដើងមេឃ" ។

"សាមបានដួលដេកស្លាប់ក្នុងព្រៃស្រោងស្រឹង ដូចជាព្រះអាទិត្យធ្លាក់ចុះលើប្រឹថពី ព្រៃនោះសឹងសម្បូរដោយម្រឹគីម្រឹគាកាចសាហាវ ថែមទាំងនៅឆ្ងាយដូចដើងមេឃ" ។

"សាមបានដួលដេកស្លាប់ប្រឡាក់ប្រឡូសដោយអាចម៍ដីក្នុងព្រៃស្រោងស្រឹងសឹងសម្បូរដោយម្រឹគីម្រឹគាកាចសាហាវ ថែមទាំងនៅឆ្ងាយដូចដើងមេឃ" ។

"សាមបានដួលដេកស្លាប់ក្នុងព្រៃស្រោងស្រឹងសឹងសម្បូរដោយម្រឹគីម្រឹគាកាចសាហាវ ថែមទាំងនៅឆ្ងាយដូចដើងមេឃ ព្រោះហេតុនោះ សូមលោកទាំងពីរនៅតែក្នុងអាស្រមនេះចុះ" ។

គ្រានោះ តាបសទាំងពីរនិយាយអះអាងនូវភាពនៃខ្លួនជាអ្នកពុំភ័យខ្លាចអំពីម្រឹគកាចសាហាវទាំងនោះ ចំពោះព្រះរាជាថា ៖

"យទិ តត្ថ សហស្សានិ សតានិ និយុតានិ ច
នេវម្ហាកំ ភយំ កោចិ វនេ វាឡេសុ វិជ្ជតិ" ។

"បើទុកណាជាព្រៃនោះ មានម្រឹគកាចសាហាវ រាប់រយ រាប់ពាន់ រាប់ម៉ឺនក៏ដោយ ក៏ទូលបង្គំទាំងពីរនាក់ ពុំមានសេចក្ដីភិតភ័យខ្លាចរអាដល់តិចតួចក្នុងតំបន់ណាឡើយ" ។

ព្រះរាជា កាលមិនអាចឃាត់តាបសទាំងពីរបាន ក៏ចាប់ដឹកដៃតាបសទាំងពីរនាំទៅក្នុងព្រៃធំ ត្រង់កន្លែងដែលសុវណ្ណសាមដេកស្លាប់ ហើយទ្រង់ប្រាប់ថា "នេះជាកូនរបស់លោកទាំងពីរ" ។ គ្រានោះ ឪពុកលើកក្បាល ម្ដាយលើកជើងដាក់លើភ្លៅ យល់ជាក់ជាសុវណ្ណសាមដួលប្រឡាក់ប្រឡូសដោយអាចម៍ដីតែម្នាក់ឯងក្នុងព្រៃធំ ហាក់ដូចព្រះចន្ទឬព្រះអាទិត្យធ្លាក់មកលើផែនដី តាបសទាំងពីរក៏អង្គុយផ្ទួងដើមដៃយំរៀបរាប់ទង្គឹះខ្សឹកខ្សួលពិលាបគួរឲ្យអាណិតថា ៖

"ពាឡ្ហំ ខោ ត្វំ បមត្តោសិ សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ ន កិញ្ចិ មភិភាសសិ ។
ពាឡ្ហំ ខោ ត្វំ បទិត្តោសិ សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ ន កិញ្ចិ មភិភាសសិ ។
ពាឡ្ហំ ខោ ត្វំ បកុទ្ធោសិ សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ ន កិញ្ចិ មភិភាសតិ ។

ពាឡ្ហំ ខោ តំ្វំ បសុត្តោសិ        សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ        ន កិញ្ចិ មភិភាសសិ ។
ពាឡ្ហំ ខោ តំ្វំ វិមនោសិ        សាម កល្យាណទស្សន
យោ អជ្ជេវំ គតេ កាលេ        ន កិញ្ចិ មភិភាសសិ ។
ជដំ វលិនំ បំសុគតំ        កោទានិ សណ្ឋបេស្សតិ
សាមោ អយំ កាលកតោ        អម្ហាកំ បរិចារកោ ។
កោ មេ សម្មជ្ជមាទាយ        សម្មជ្ជិស្សតិ អស្សមំ
សាមោ អយំ កាលកតោ        អម្ហាកំ បរិចារកោ ។
កោទានិ ន្ហាបយិស្សតិ        សីតេនុណ្ហោទកេន ច
សាមោ អយំ កាលកតោ        អម្ហាកំ បរិចារកោ ។
កោទានិ ភោជយិស្សតិ        វនមូលផលានិ ច
សាមោ អយំ កាលកតោ        អម្ហាកំ បរិចារកោ" ។

*"ហៃកូន ការស្លាប់នេះមិនសមសោះ ។ ហៃបាសាម អ្នកមានរូបល្អ ជាទីពិតពិលរមិលមើល បាងង៉ភ្លេចស្មារតីពេកទេដឹង ទើបបានជាដល់ក្ដីស្លាប់ក្នុងថ្ងៃនេះ មិននិយាយរកយើងបន្តិចបន្តួចសោះ ដូចជាភ្លេចស្មារតីព្រោះផឹកសុរាសជាតិខ្លាំង ។ ហៃបាសាម អ្នកមានរូបល្អ ជាទីពិតពិលរមិលមើល បាងង៉ភ្លើតភ្លើនពេកទេដឹង ទើបបានជាដល់ក្ដីស្លាប់ក្នុងថ្ងៃនេះ មិននិយាយរកយើងបន្តិច*

បន្ទួចសោះ ។ ឱបាសាម អ្នកមានរូបល្អ ជាទីពិតពិលរមិលមើល បាឯងខឹងខ្ញាំងពេកទេដឹង ទើបបានជាដល់ក្តីស្លាប់ក្នុងថ្ងៃនេះ មិននិយាយរកយើងបន្តិចបន្ទួចសោះ ។ ឱបាសាម អ្នកមានរូបល្អ ជាទីពិតពិលរមិលមើល បាឯងដេកលក់ស៊ប់ពេកទេដឹង ទើបបានជាដល់ក្តីស្លាប់ក្នុងថ្ងៃនេះ មិននិយាយរកយើងបន្តិចបន្ទួចសោះ។ ឱបាសាម អ្នកមានរូបល្អ ជាទីពិតពិលរមិលមើល បាឯងអាក់អន់ចិត្តពេកទេដឹង ទើបបានជាដល់ក្តីស្លាប់ក្នុងថ្ងៃនេះ មិននិយាយរកយើងបន្តិចបន្ទួចសោះ ។ ឥឡូវនេះ តើនឹងបាននរណា រៀបចំជម្រះធ្វើឲ្យត្រង់នូវផ្នួងសក់របស់យើង ដែលប្រឡាក់ប្រឡូសដោយមន្ទិលអាចម៍ដី ព្រោះសាម ដែលតែងតែបម្រើយើងជាមនុស្សងងឹតនេះ ដល់នូវសេចក្តីស្លាប់ហើយ ។ តើបាននរណានឹងបោសសម្អាតអាស្រមឲ្យយើង ព្រោះសាម ដែលតែងតែបម្រើយើងជាមនុស្សងងឹតនេះ ដល់នូវសេចក្តីស្លាប់ហើយ ។ ឥឡូវនេះ តើនឹងបាននរណាបម្រើទឹកក្តៅទឹកត្រជាក់ដល់យើង ព្រោះសាម ដែលតែងតែបម្រើយើងជាមនុស្សងងឹតនេះ ដល់នូវសេចក្តីស្លាប់ហើយ ។ ឥឡូវនេះ តើនឹងបាននរណាឲ្យយើងបរិភោគ មើមឈើផ្លែឈើ ព្រោះសាមដែលតែងតែបម្រើយើងជាមនុស្សងងឹតនេះ ដល់នូវសេចក្តីស្លាប់ហើយ" ។

## ជនទាំង ៣ ធ្វើសច្ចាធិដ្ឋាន

គ្រានោះ ម្ដាយសុវណ្ណសាម ពិលាប[៣១] រៀបរាប់ជាច្រើន យកដៃដាក់លើទ្រូងកូនស្ទង់មើលកម្ដៅ ហើយគិតថា "ខ្លួនកូនអញនៅតែមានកម្ដៅនៅឡើយ, ប្រហែលជាគេមិនទាន់ស្លាប់ទេ គឺគ្រាន់តែសន្លប់បាត់ស្មារតីដោយកម្លាំងពិសទេដឹង ដូច្នេះ អញគួរតែធ្វើសច្ចកិរិយា ដើម្បីបន្សាបពិសឲ្យអស់ពីខ្លួនគេ" រួចអធិដ្ឋានដូចតទៅ ៖

"យេន សច្ចេនយំ សាមោ ធម្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ ព្រហ្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ សច្ចវាទី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ មាតាបេត្តិភរោ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ កុលេ ជេដ្ឋាបចាយិកោ

---

[៣១] (ន.) សេចក្ដីខ្សឹកខ្សួលរៀបរាប់, ដំណើរយំបូរបាច់ឮខ្លាំង ៗ ដោយស្ដាយអាល័យ ឬដោយកើតទុក្ខតូចចិត្តណាស់ ។ ខ្មែរច្រើនប្រើជា កិ. ឬ កិ. វិ. : ពិលាបសោកស្ដាយ; យំពិលាប, ទួញពិលាប ។

ឯតេន សច្ចវជ្ជេន　　　　វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ　　ធាណា បិយតរោ មម
ឯតេន សច្ចវជ្ជេន　　　　វិសំ សាមស្ស ហញ្ញតុ ។
យំ កិញ្ចិត្ថិ កតំ បុញ្ញំ　　មយ្ហញ្ចេវ បិតុច្ច តេ
សព្វេន តេន កុសលេន　　វិសំ សាមស្ស ហញ្ញតុ" ។

"ក្នុងកាលមុន សាមនេះ ជាអ្នកប្រតិបត្តិធម៌ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ គឺកុសលកម្មបថ ១០ ជាអ្នកពោលនូវពាក្យសត្យ ទាក់ទងនឹងប្រយោជន៍ មិនពោលនូវពាក្យកុហក ជាអ្នកបម្រើម្ដាយឪពុក ទាំងពេលយប់ទាំងពេលថ្ងៃ ដោយសេចក្ដីមិនខ្ជិលច្រអូស ជាអ្នកប្រព្រឹត្តកោតក្រែងធ្វើសក្ការៈដល់បុគ្គលជាធំក្នុងត្រកូល គឺម្ដាយឪពុក ដោយការពោលនូវពាក្យសច្ចៈនេះ សូមឲ្យពិសដែលមានក្នុងខ្លួនរបស់សាម សាបរលាបទៅ ។ សាមនេះ ជាទីស្រឡាញ់ដោយវិសេស ជាងជីវិតរបស់ខ្ញុំ ដោយការពោលនូវពាក្យសច្ចៈនេះ សូមឲ្យពិសដែលមានក្នុងខ្លួនរបស់សាម សាបរលាបទៅ ។ បុណ្យណាទីមួយដែលខ្ញុំផង ដែលឪពុករបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសដែលមានក្នុងខ្លួនរបស់សាមសាបរលាបទៅ" ។

កាលម្ដាយធ្វើសច្ចកិរិយាដោយ ៧ គាថាយ៉ាងនេះហើយ, សុវណ្ណសាមក៏ប្រែខ្លួនដេក ។ គ្រានោះ ឪពុករបស់សុវណ្ណសាមគិតថា "អ្ហា ! កូនអញនៅមានជីវិតទេតើ អញនឹងធ្វើសច្ចកិរិយាបន្ថែមទៀត ដើម្បីជួយសុវណ្ណសាម" រួចគាត់ក៏ធ្វើសច្ចកិរិយាតាមលម្អានតាបសិនីដូច្នេះ ៖

"យេន សច្ចេនយំ សាមោ ធម្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ ព្រហ្មចារី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ សច្ចវាទី បុរេ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ មាតាបេត្តិភរោ អហុ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ កុលេ ជេដ្ឋាបចាយិកោ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យេន សច្ចេនយំ សាមោ បាណា បិយតរោ មម
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
យំ កិញ្ចិត្ថិ កតំ បុញ្ញំ មយ្ហញ្ចេវ មាតុច្ច តេ
សព្វេន តេន កុសលេន វិសំ សាមស្ស ហញ្ញតុ" ។

"ក្នុងកាលមុន សាមនេះ ជាអ្នកប្រតិបត្តិធម៌ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកពោលនូវពាក្យសត្យ ជាអ្នកបម្រើម្តាយឪពុក ជាអ្នកប្រព្រឹត្តកោតក្រែងបុគ្គលជាធំក្នុងត្រកូល ដោយការពោលនូវពាក្យសច្ចៈនេះ សូមឲ្យពិសដែលមានក្នុងខ្លួនរបស់សាម សាបរលាបទៅ ។ សាមនេះ ជាទីស្រឡាញ់ដោយវិសេស ជាងជីវិតរបស់ខ្ញុំ ដោយការពោលនូវពាក្យសច្ចៈនេះ សូមឲ្យពិសដែលមានក្នុងខ្លួនរបស់សាម សាបរលាបទៅ ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលម្តាយរបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសដែលមានក្នុងខ្លួនរបស់សាមសាបរលាបទៅ" ។

កាលបើតាបសជាឪពុកធ្វើនូវសច្ចកិរិយាយ៉ាងនេះ ព្រះមហាសត្តបានប្រែខ្លួនទៅម្ខាងទៀត ។ បន្ទាប់មក ទេវតាពហុសុន្ទរីដែលនៅអាស្រ័យលើភ្នំគន្ធមាទន៍ បានមកបង្ហាញខ្លួនចំពោះមុខជនទាំងនោះ ហើយធ្វើនូវសច្ចកិរិយាលើកទី ៣ ដើម្បីអនុគ្រោះសុវណ្ណសាមដែរថា៖

"បព្វត្យាហំ គន្ធមាទនេ ចិររត្តនិវាសិនី
ន មេ បិយតរោ កោចិ អញ្ញោ សាមេន វិជ្ជតិ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ ។
សព្វេ វនា គន្ធមយា បព្វតេ គន្ធមាទនេ
ឯតេន សច្ចវជ្ជេន វិសំ សាមស្ស ហញ្ញតុ" ។

"ខ្ញុំបាននៅអាស្រ័យលើភ្នំគន្ធមាទន៍នេះ អស់កាលជាយូរអង្វែង ហើយ ឥតមានអ្នកដទៃណាជាទីស្រឡាញ់របស់ខ្ញុំវិសេសជាង សាមនេះទេ ដោយការពោលនូវពាក្យសច្ចៈនេះ សូមឲ្យពិសក្នុង ខ្លួនសាម សាបរលាបទៅ ។ នៅភ្នំគន្ធមាទន៍នេះ សព្វព្រៃព្រឹក្សា ទាំងឡាយសុទ្ធសឹងមានក្លិនក្រអូប ពុំមានឈើណាមួយឥតក្លិន ក្រអូបនៅទីនោះទេ ដោយការពោលនូវពាក្យសច្ចៈនេះ សូមឲ្យ ពិសក្នុងខ្លួនសាម វិនាសសាបសូន្យទៅ" ។

## សុវណ្ណសាមដឹងស្មារតីឡើងវិញ

កាលបើតាបសទាំង ២ រូបនោះ កំពុងពិលាបរៀបរាប់នូវពាក្យ ប្រកបដោយសេចក្តីករុណាយ៉ាងច្រើនបែបនេះ និងក្នុងពេលចប់សច្ចកិរិយារបស់ទេវតា សុវណ្ណសាមកំលោះ មានរូបល្អ គួរពិតពិលរមិល មើល ក៏ក្រោកឡើងភ្លាម ក្នុងទីនោះ, ពិសក្នុងខ្លួនក៏ប្រែជាសាបរលាប អាពាធការឈឺចាប់ ក៏ជាស្រឡះផង បីដូចទឹករអិលធ្លាក់ពីស្លឹកឈូក ស្វាកស្វាមមុតសរ ក៏ឥតឃើញប្រាកដត្រង់នេះត្រង់នោះ ។

ហេតុអស្ចារ្យ ៤ យ៉ាងក៏កើតឡើងក្នុងពេលដំណាលគ្នាគឺ ៖

១- ព្រះមហាសត្តបានជាសះស្បើយស្រឡះដូចដើម

២- ភ្នែកទាំង ៤ របស់ម្តាយឪពុកសុវណ្ណសាម បានភ្លឺឡើងវិញ

៣- ព្រះអរុណក៏រះឡើង

*៤- ជនទាំង ៤ នាក់នោះ ក៏មានប្រាកដក្នុងអាស្រម ដោយ អានុភាពនៃទេវតា*

*ម្ដាយឪពុកសាមត្រេកអរយ៉ាងក្រៃលែងថា "ភ្នែកយើងភ្លឺវិញហើយ, ទាំងសុវណ្ណសាមកូនយើងក៏ជារបួសដែរ" ។ គ្រានោះ សាមបណ្ឌិត បានពោលចំពោះជនទាំងនោះថា ៖*

"សាមោហមស្មិ ភទ្ទំ វោ　　សោត្ថិនាម្ហិ សមុដ្ឋិតោ
មា ពាឡ្ហំ បរិទេវេថ　　មញ្ជុនាភិវទេថ មំ" ។

*"ខ្ញុំឈ្មោះសាម សេចក្ដីចម្រើនចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងដោយសុខសួស្ដីហើយ សូមលោកទាំងឡាយឈប់ខ្សឹកខ្សួលទៀតទៅ សូមលោកទាំងឡាយនិយាយមករកខ្ញុំដោយទឹកមុខរីករាយ" ។*

*គ្រានោះ សុវណ្ណសាមបានធ្វើបដិសណ្ឋារកិច្ចចំពោះព្រះរាជាហើយ ក្រាបទូលថា ៖*

"ស្វាគតំ តេ មហារាជ　　អថោ តេ អទុរាគតំ
ឥស្សរោសិ អនុប្បត្តោ　　យំ ឥធត្ថិ បវេទយ ។
តិន្ទុកានិ បិយាលានិ　　មធុកេ កាសុមារិយោ
ផលានិ ខុទ្ទកប្បានិ　　ភុញ្ជ រាជ វរំ វរំ ។

អត្ថិ មេ ចានីយំ សីតំ អាភតំ គិរិគព្ភរា
តតោ បិវ មហារាជ សចេ ត្វំ អភិកង្ខសិ" ។

"បពិត្រមហារាជ ព្រះរាជដំណើររបស់ព្រះអង្គមកក្នុងទីនេះ ល្អហើយ ទ្រង់យាងមកនេះ មិនអាក្រក់ទេ ព្រះអង្គជាធំទ្រង់យាងមកដល់ហើយ ព្រះអង្គមានសេចក្ដីត្រូវការដោយវត្ថុណាដែលមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូលមកចុះ ។ បពិត្រមហារាជ ផលាផល មានផ្លែទន្លាប់ មាក់ប្រ៉ែន ស្រគំ សឹងមានរសផ្អែមល្ហុយឆ្ងាញ់ រីឯទឹកដែលទូលព្រះបង្គំបាននាំមកអំពីជ្រោះភ្នំ មានភាពត្រជាក់គួរសោយ សូមព្រះអង្គទ្រង់សោយតាមសប្បាយក្នុងព្រះទ័យចុះ ក្រាបទូល" ។

ចំណែកព្រះរាជាទតឃើញនូវភាពអស្ចារ្យនោះ ទ្រង់បានត្រាស់ថា ៖

"សម្មុយ្ហាមិ បមុយ្ហាមិ សព្វា មុយ្ហន្តិ មេ ទិសា
បេតំ តំ សាម មទ្ទក្ខិំ កោ នុ ត្វំ សាម ជីវសិ" ។

"នែសាម ខ្ញុំភាន់ភាំងស្មារតី វង្វេងទិសអស់ហើយ ព្រោះបានឃើញសាមធ្វើមរណកាលហើយ ម្ដេចទើបអ្នករស់ឡើងវិញ ?"

សុវណ្ណសាមគិតថា "ព្រះរាជាអង្គនេះ សម្គាល់ថាអញស្លាប់ អញនឹងប្រកាសអំពីភាពនៃខ្លួនដែលមិនទាន់ស្លាប់" ហើយក៏ក្រាបទូលថា ៖

"អបិ ជីវំ មហារាជ　　បុរិសំ គាឡ្ហវេទនំ
ឧបនីតមនសង្កប្បំ　　ជីវន្តំ មញ្ញតេ មតំ ។
អបិ ជីវំ មហារាជ　　បុរិសំ គាឡ្ហវេទនំ
តំ និរោធគតំ សន្តំ　　ជីវន្តំ មញ្ញតេ មតំ" ។

*"បពិត្រមហារាជ សត្វលោកតែងសម្គាល់នូវបុរសដែលនៅមានជីវិត តែមានទុក្ខវេទនាធ្ងន់គ្របសង្កត់ ឬមានចិត្តធ្លាក់ចុះក្នុងភវង្គ[៣២]ថា "ស្លាប់" ។ បពិត្រមហារាជ ម្យ៉ាងទៀត សត្វលោកតែងសម្គាល់នូវបុរសដែលនៅរស់ តែមានទុក្ខវេទនាធ្ងន់គ្របសង្កត់ ឬចូលនិរោធសមាបត្តិស្ងប់រលត់ខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលថា "ស្លាប់" សត្វលោកតែងសម្គាល់ខ្ញុំដែលកំពង់រស់ថាស្លាប់យ៉ាងនេះ" ។*

[៣២] *អង្គនៃភព ។ តាមគោលនៃព្រះអភិធម្មបានសម្ដែងថា ចិត្តដែលនៅត្រង់រវាងចន្លោះបដិសន្ធិនិងចុតិ គឺមានតាំងពីកើតរហូតដល់ស្លាប់ ក្នុងវេលាដែលមិនបានសោយអារម្មណ៍តាមទ្វារទាំង ៦ មានចក្ខុទ្វារជាដើម ។ តែកាលណាបើមានការទទួលអារម្មណ៍ដូចជាបានឃើញនិងបានឮជាដើម ក៏កើតជាវិថីចិត្តឡើងជំនួសឲ្យភវង្គចិត្ត ។ កាលបើវិថីចិត្តរលត់ទៅ ក៏កើតជាភវង្គចិត្តឡើងដូចដើម ។*

**សុវណ្ណសាមថ្វាយរាជធម៌**

*លុះពោលយ៉ាងនេះហើយ សុវណ្ណសាមមានបំណងចង់ឲ្យព្រះរាជាទទួលបាននូវប្រយោជន៍, ទើបសម្ដែងព្រះធម៌ថ្វាយបន្តទៀតថា ៖*

"យោ មាតរំ បិតរំ វា　　មច្ចោ ធម្មេន បោសតិ
ទេវាបិ នំ តិកិច្ឆន្តិ　　មាតាបេត្តិភរំ នរំ ។
យោ មាតរំ បិតរំ វា　　មច្ចោ ធម្មេន បោសតិ
ឥធេវ នំ បសំសន្តិ　　បេច្ច សគ្គេ បមោទតិ" ។

*"សត្វណា តែងចិញ្ចឹមនូវមាតានិងបិតាដោយធម៌ ទេវតាទាំងឡាយ តែងរក្សានូវសត្វនោះ ។ សត្វណា តែងចិញ្ចឹមមាតានិងបិតាដោយធម៌ បណ្ឌិតទាំងឡាយក្នុងលោកនេះឯង តែងសរសើរនូវសត្វនោះ សត្វនោះលុះលះបង់លោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌" ។*

*ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវឱវាទជាធម៌នោះហើយ មានព្រះតម្រិះថា "អស្ចារ្យម៉្លេះហ្ន៎ ! ទេវតាទាំងឡាយ តែងព្យាបាលនូវរោគដែលកើតឡើងដល់ជនអ្នកចិញ្ចឹមម្ដាយឪពុក, សាមនេះពិតជារុងរឿងក្រៃលែងណាស់" ផ្គងអញ្ជលីហើយសំណូមពរថា ៖*

"ឯស ភិយ្យោ បមុយ្ហាមិ　　សព្វា មុយ្ហន្តិ មេ ទិសា
សរណំ តំ សាម គច្ឆាមិ　　ត្វញ្ច មេ សរណំ ភវ" ។

*"ព្រោះហេតុតែខ្ញុំបានប្រព្រឹត្តខុសចំពោះអ្នកដែលបរិបូណ៌ដោយសីលគុណបរិសុទ្ធដូច្នោះ ទើបខ្ញុំរឹងរឹតតែភាន់កាំងស្មារតី វង្វេងទិសអស់ ម្នាលសាម ខ្ញុំសូមយកអ្នកជាទីពឹង អ្នកចូរជាទីពឹងរបស់ខ្ញុំ សូមជួយបង្ហាញផ្លូវទៅកាន់ទេវលោក" ។*

*គ្រានោះ ព្រះមហាសត្តក្រាបទូលថា ៖*

*"បពិត្រមហារាជ ប្រសិនបើព្រះអង្គមានព្រះរាជបំណងចង់ទៅកាន់ទេវលោក ចង់សោយនូវទិព្វសម្បត្តិដ៏ធំ, សូមទ្រង់អនុវត្តនូវរាជធម៌ ១០ ប្រការដូចតទៅ" ៖*

"ធម្មំ ចរ មហារាជ　　មាតាបិតូសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន　　រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ　　បុត្តទារេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន　　រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ　　មិត្តាមច្ចេសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន　　រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ　　វាហនេសុ ពលេសុ ច

ឥធ ធម្មំ ចរិត្វាន     រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ     គាមេសុ និគមេសុ ច
ឥធ ធម្មំ ចរិត្វាន     រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ     រដ្ឋេសុ ជនបទេសុ ច
ឥធ ធម្មំ ចរិត្វាន     រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ     សមណព្រាហ្មណេសុ ច
ឥធ ធម្មំ ចរិត្វាន     រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ     មិគបក្ខីសុ ខត្តិយ
ឥធ ធម្មំ ចរិត្វាន     រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ     ធម្មោ ចិណ្ណោ សុខាវហោ
ឥធ ធម្មំ ចរិត្វាន     រាជ សគ្គំ គមិស្សសិ ។
ធម្មំ ចរ មហារាជ     សឥន្ទា ទេវា សព្រហ្មកា
សុចិណ្ណេន ទិវំ បត្តា     មា ធម្មំ រាជ ប្បាមទោ” ។

“បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមាតា និងបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះបុត្រនិងភរិយា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់

ឋានសួគ៌ ។ បពិត្រមហារាជ ជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមិត្រនិងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសត្វពាហនៈនិងពល បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះស្រុកនិងនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែននិងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជាលុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសមណៈនិងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជសូមព្រះអង្គប្រព្រឹត្តធម៌ចំពោះម្រឹគនិងបក្សី បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រ

មហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ធម៌ដែលប្រព្រឹត្តល្អហើយតែង
នាំមកនូវសុខ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុង
លោកនេះហើយ នឹងទៅកាន់ឋានសួគ៌ ។ បពិត្រមហារាជ សូម
ព្រះអង្គប្រព្រឹត្តធម៌ ព្រោះទេវតាឥន្ទព្រហ្មដែលបានដល់នូវឋាន
សួគ៌ ក៏ព្រោះធម៌ដែលខ្លួនប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា
ព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ" ។

អត្ថន័យនៃគាថាទាំងនេះ មានបែងពិស្តាររួចហើយ ក្នុង
តេសកុណជាតក ។

លុះសម្តែងនូវរាជធម៌ ១០ ប្រការថ្វាយព្រះមហាក្សត្រស្តេចផែនដី
យ៉ាងនេះហើយ សុវណ្ណសាមបានផ្តល់ដំបូន្មានបន្ថែមទៀត ហើយឲ្យ
នូវសីល ៥ ។ ព្រះរាជាស្តេចបីឡិយក្ស ទទួលឱវាទរបស់សុវណ្ណសាម
ដោយសិរសា ថ្វាយបង្គំសូមខមាទោសព្រះមហាសត្តហើយ ស្តេចទ្រង់
យាងទៅកាន់ក្រុងពារាណសីវិញ ខិតខំសាងព្រះរាជកុសលទាំងឡាយ
មានការប្រទានអំណោយជាដើម ហើយក៏បានទៅកាន់ឋានសួគ៌
នាពេលអស់ព្រះជន្ម ។ ចំណែក សុវណ្ណសាមព្រះពោធិសត្វនៃយើង
លោកប្រណិប័តន៍បម្រើម្តាយឪពុករហូតអស់ជីវិត, បានញុំាងអភិញ្ញា

៥ និងសមាបត្តិ ៨ ឲ្យកើតឡើង ជាមួយនឹងម្តាយឪពុក, លុះដល់ទីបំផុតព្រះជន្ម ក៏ទៅកើតនៅឯព្រហ្មលោកនាយ ។

## ព្រះសាស្តាប្រជុំជាតក

កាលព្រះសាស្តា ស្តេចទ្រង់នាំធម្មទេសនានេះ មកបរិយាយហើយ ទ្រង់បញ្ជាក់ថា "ម្នាលភិក្ខុទាំងឡាយ ជាធម្មតា ការចិញ្ចឹមម្តាយឪពុក គឺជាវង្សរបស់បណ្ឌិត" រួចទ្រង់ប្រកាសចតុរារិយសច្ចៈ ។

ក្នុងពេលសម្តែងសច្ចៈចប់ ភិក្ខុចិញ្ចឹមម្តាយ បានសម្រេចសោតាបត្តិផល ។ ព្រះសាស្តាទ្រង់ប្រជុំជាតកក្នុងពេលនោះថា ៖

តទា រាជា អានន្ទោ អហោសិ, ទេវធីតា ឧប្បលវណ្ណា,
សក្កោ អនុរុទ្ធោ, ទុក្ខុលបណ្ឌិតោ មហាកស្សបោ,
ចារិកា ភទ្ទកាបិលានី ភិក្ខុនី, សុវណ្ណសាមបណ្ឌិតោ
បន អហមេវ សម្មាសម្ពុទ្ធោ អហោសិ ។

- ស្តេចផែនដីបីឡិយក្សត្រនោះ បានជាអានន្ទ
- ទេពធីតា បានមកជាឧប្បលវណ្ណាថេរី,
- សក្កទេវរាជ បានមកជាអនុរុទ្ធ,
- ទុក្ខុលតាបស បានមកជាមហាកស្សបត្ថេរ,
- បារិកា បានមកជាភទ្ទកាបិលានីភិក្ខុនី,

- ចំណែកឯបណ្ឌិតសុវណ្ណសាម គឺជាតួអង្គអញ្ញតថាគតអរហន្ត សម្មាសម្ពុទ្ធនេះឯង ។

សុវណ្ណសាមជាតកពិស្តារ ចប់តែប៉ុណ្ណេះ ។

PAÑÑĀSĀSTRA UNIVERSITY



នេះកាលកិន្នរកិន្នរីនាំព្រះសុវណ្ណសាម
ទៅងូតទឹក និងថែរក្សា

ISBN 9789996341014

PUC Press